ក្រសួងអប់រំ យុវជន និងកីឡា

# ឈ្វេងយល់ការផាត់ចេញពីសង្គម នៅក្នុងបរិបទកម្ពុជា និងផែនការ សម្រាប់ការអប់រំបរិយាបន្ន

ខែសីហា ឆ្នាំ២០២១

ក្រសួងអប់រំ យុវជន និងកីឡា
នាយកដ្ឋានគោលនយោបាយ

# ស្វែងយល់ការផាត់ចេញពីសង្គមនៅក្នុងបរិបទកម្ពុជា និងផែនការសម្រាប់ការអប់រំបរិយាបន្ន

បោះពុម្ពនៅភ្នំពេញ
ក្រសួងអប់រំ យុវជន និងកីឡា
ភ្នំពេញ ប្រទេសកម្ពុជា

ដើម្បីដកស្រង់សៀវភៅនេះ៖ ក្រសួងអប់រំ យុវជន និងកីឡា. (២០២១). *ស្វែងយល់ការផាត់ចេញពីសង្គមនៅក្នុងបរិបទកម្ពុជា និងផែនការសម្រាប់ការអប់រំបរិយាបន្ន*. ភ្នំពេញ ប្រទេសកម្ពុជា នាយកដ្ឋានគោលនយោបាយ ក្រសួងអប់រំ យុវជន និងកីឡា

# មាតិកា

**មាតិកា** ........................................................................................ i
**បុព្វកថា**........................................................................................ iii
**ពន្យល់ពាក្យ**........................................................................................ iv

**ជំពូក ១ សេចក្តីផ្តើម** ........................................................................................ ១
១.១- ការអប់រំបរិយាបន្ន: ការប្តេជ្ញាចិត្តជាសកលនិងសម្រាប់កម្ពុជា ........................... ១
១.២- បញ្ហាប្រឈមនៃការអប់រំបរិយាបន្ន ........................................................ ២

**ជំពូក ២ ឈ្វេងយល់ពីការផាត់ចេញពីសង្គមនៅកម្ពុជា**........................... ៤
២.១- និយមន័យ ........................................................................................ ៤
២.២- ការផាត់ចេញពីសង្គមក្នុងវិស័យអប់រំ .................................................... ៥
២.២.១- ពិការភាព........................................................................................ ៥
២.២.២- ក្រុមជនជាតិដើមភាគតិច .................................................................... ៦
២.២.៣- សមភាពយេនឌ័រ .................................................................................. ៧
២.២.៤- និន្នាការភេទ ........................................................................................ ៨
២.២.៥- ស្ថានភាពជំងឺអេដស៍........................................................................... ៩
២.៣- ភាពស្មុគស្មាញនៃការផាត់ចេញពីសង្គម.................................................... ៩

**ជំពូក ៣ ការផ្លាស់ប្តូរពីការផាត់ចេញពីសង្គមទៅជាការអប់រំបរិយាបន្ន**.. ១១
៣.១- គោលនយោបាយស្តីពី ការអប់រំបរិយាបន្ន................................................ ១១
៣.២- ផែនការសម្រាប់ការអប់រំបរិយាបន្ននៅគ្រប់កម្រិតសិក្សា ............................... ១២
៣.២.១- ការវិភាគការផាត់ចេញពីសង្គម និងយេនឌ័រ (SEGA)....................... ១២
៣.៣- ការផាត់ចេញពីសង្គមទៅជាការអប់រំបរិយាបន្ននៅថ្នាក់ភូមិ និងសាលារៀន
បទពិសោធពីខេត្តរតនគិរី......................................................................... ១៣
៣.៣.១- ភាសាដែលត្រូវបានប្រើក្នុងថ្នាក់រៀន (ភាសាឡាវ ទំពួន និងចារាយ) .... ១៤
៣.៣.២- ហេដ្ឋារចនាសម្ព័ន្ធសាលារៀន.................................................... ១៤

៣.៣.៣- សាសនា និងវប្បធម៌ផ្សេងៗគ្នាត្រូវបានផាត់ចេញពីសង្គម .................. ១៥
៣.៣.៤- ការផ្តល់សេវាអប់រំនៅក្នុងសាលារៀននិងការរៀនមិនគ្រប់គ្រាន់............ ១៥
៣.៣.៥- កង្វះសេរីភាពនិងសមភាពក្នុងបរិបទថ្នាក់រៀន ................................. ១៥
៣.៣.៦- បច្ចេកវិទ្យា ........................................................................... ១៦
៣.៣.៧- កង្វះខាតស្តង់ដាគ្រូ និងគំរូមិនល្អគ្រប់គ្រាន់ .................................... ១៦
៣.៣.៨- និន្នាការនយោបាយរវាងគ្រូបង្រៀន សិស្ស និងស្ថាប័នគ្រប់គ្រង........... ១៧
**៣.៤- ប្រព័ន្ធអប់រំដាច់ដោយឡែក និងប្រព័ន្ធអប់រំបរិយាបន្ននៅកម្រិតការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលខណ្ឌ-ក្រុង-ស្រុក (DOE) ................................ ១៧**
៣.៤.១- កង្វះការយល់ដឹងនៅក្នុងសហគមន៍ទាក់ទងនឹងតម្រូវការនៃការអប់រំល្អ .. ១៧
៣.៤.២- ឪពុកម្តាយរបស់សិស្សដែលមិនបានទទួលការអប់រំ និងមានមុខរបរមិនច្បាស់លាស់ ........................................................................ ១៨
**៣.៥- ការផាត់ចេញពីប្រព័ន្ធអប់រំ ទៅជាប្រព័ន្ធអប់រំបរិយាបន្ននៅកម្រិតមន្ទីរ អយក ខេត្ត (POE) ........................................................................ ១៨**
៣.៥.១- សាលារៀនខ្លះមិនមាននាយកសាលានិងជួលតែគ្រូបង្រៀនក្នុងស្រុកមួយចំនួនតូច ........................................................................ ១៨
៣.៥.២- ការអភិវឌ្ឍក្នុងស្រុកយឺត.......................................................... ១៩
៣.៥.៣- ការធ្វើផែនការផ្តែកលើភ័ស្តុតាង និងគុណភាព ................................ ១៩
**៣.៦- កម្រិតក្រសួងអប់រំ យុវជន និងកីឡា...................................................២០**
៣.៦.១- ការអប់រំបរិយាបន្ន .................................................................. ២០
៣.៦.២- ការអប់រំពហុភាសា.................................................................. ២០
៣.៦.៣- សមភាពយេនឌ័រ..................................................................... ២០
៣.៦.៤- ទំនោរផ្លូវភេទ (រួមទាំងមេរោគអេដស៍) ........................................... ២១
**ជំពូក ៤ សេចក្តីសន្និដ្ឋាន និងមាគ៌ាឆ្ពោះទៅមុខ.......................................២២**
**ឯកសារយោង ......................................................................២៣**

# បុព្វកថា

ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតគោលនយោបាយស្តីពី ការអប់រំកុមារពិការ ក្នុងឆ្នាំ ២០០៨ និងបានកែសម្រួលទៅជាគោលនយោបាយស្តីពី ការអប់រំបរិយាបន្ន នៅឆ្នាំ២០១៨។ គោលបំណងនៃការកែសម្រួលគោលនយោបាយគឺ ដើម្បីធានាថា បុគ្គលដែលមានតម្រូវការអប់រំពិសេសអាចអភិវឌ្ឍជំនាញ និងឥរិយាបថដែលត្រូវការ ដើម្បីក្លាយជាពលរដ្ឋសកម្មក្នុងសង្គមនៃវិបុលភាពរួមគ្នា។

ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជាឆ្នាំ២០៣០ ដែលប្តេជ្ញាសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ត្រូវបានរៀបចំឡើងនៅឆ្នាំ២០១៩ និងផ្តោតសំខាន់ទៅលើការផ្តល់ការអប់រំ ដែលមានលក្ខណៈបរិយាបន្ន សមធម៌ និងគុណភាពសម្រាប់មត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា ក៏ដូចជាការអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ។ ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជាឆ្នាំ២០៣០ រួមបញ្ចូលទាំងការលើកកម្ពស់ការរៀនសូត្រពេញមួយជីវិត ដើម្បីបង្កើនផលិតភាពការងារក្នុងការគាំទ្រដល់វិបុលភាពសេដ្ឋកិច្ច និងសង្គម។

*"ការយល់ដឹងយល់ពីការផាត់ចេញពីសង្គមនៅក្នុងបរិបទកម្ពុជា និងផែនការសម្រាប់ការអប់រំបរិយាបន្ន "* គូសបញ្ជាក់ពីកត្តាផាត់ចេញ ដែលរាំងបុគ្គល ឬក្រុម ពីការចូលរួមក្នុងជីវិតសេដ្ឋកិច្ច សង្គម នយោបាយ និងវប្បធម៌នៃសង្គមរបស់ពួកគេ។ ឯកសារនេះក៏ផ្តល់នូវចំណេះដឹងទូលំទូលាយលើបុព្វហេតុនៃការផាត់ចេញពីសង្គម ក្នុងប្រព័ន្ធអប់រំដែលកុមារនៅកម្ពុជាធ្លាប់ឆ្លងកាត់កន្លងមក។

ឯកសារនេះនឹងជួយដល់បុគ្គលិកអប់រំថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមមានបុគ្គលិកអប់រំដែលបម្រើការនៅមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ ព្រមទាំងនាយកសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ដែលចង់ដឹងបន្ថែមអំពីការផាត់ចេញពីសង្គម និងការអប់រំបរិយាបន្ន។ គោលបំណងនៃឯកសារនេះក៏ជួយគាំទ្រដល់អ្នកដែលចង់ដោះស្រាយបញ្ហាការផាត់ចេញពីសង្គម និងការវិភាគយេនឌ័រ តាមរយៈការស្រាវជ្រាវប្រតិបត្តិ ដើម្បីនាំមកនូវវឌ្ឍនភាពជាវិជ្ជមាននៅក្នុងប្រព័ន្ធអប់រំផងដែរ។

ក្រសួងសង្ឃឹមថា ឯកសារនេះនឹងជួយឱ្យអ្នកអានពង្រីកចំណេះដឹងទាក់ទងនឹងការផាត់ចេញពីសង្គមរបស់កុមារពីការអប់រំ ហើយឆ្ពោះទៅរកការអប់រំបរិយាបន្ននៅក្នុងប្រទេសកម្ពុជា។ ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រុមការងារបច្ចេកទេស អ្នកពាក់ព័ន្ធ និងដៃគូអភិវឌ្ឍសម្រាប់ការលះបង់ពេលវេលាដ៏មានតម្លៃ កម្លាំងកាយ កម្លាំងចិត្ត និងបញ្ញាដើម្បីអភិវឌ្ឍឯកសារនេះឡើង។

ថ្ងៃព្រហស្បតិ៍ ១១កើត ខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ សីហា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# ពន្យល់ពាក្យ

| | |
|---|---|
| **ការស្រាវជ្រាវប្រតិបត្តិ** | ការស្រាវជ្រាវប្រតិបត្តិពិពណ៌នាអំពីការសិក្សាស្រាវជ្រាវខ្នាតតូច និងការចូលរួមបែបប្រជាធិបតេយ្យ ដែលត្រូវបានអនុវត្តយ៉ាងងាយ តាមរយៈការសម្ភាស និងពិភាក្សាក្រុម។ ការស្រាវជ្រាវប្រតិបត្តិត្រូវបានប្រើនៅកន្លែង ដែលមនុស្សស្វែងរកការអនុវត្តឈានទៅរកវឌ្ឍនភាពជាវិជ្ជមាននៅក្នុងការអនុវត្តផ្ទាល់ខ្លួន សាលារៀន សហគមន៍ ឬនៅក្នុងអង្គភាពរបស់ពួកគេ។ ការវិភាគការផាត់ចេញពីសង្គម និងយេនឌ័រ ត្រូវបានធ្វើឡើងតាមរយៈការស្រាវជ្រាវប្រតិបត្តិ។ |
| **ជនជាតិភាគតិច** | ជនជាតិចិន ចាម និងវៀតណាម គឺជាជនជាតិភាគតិចដែលរស់នៅក្នុងប្រទេសកម្ពុជា។ ពួកគេខុសគ្នាពីក្រុមជនជាតិដើមភាគតិចនៅក្នុងកម្ពុជាតាមរយៈប្រវត្តិសាស្ត្រ របៀបរស់នៅ និងការទទួលអនុវត្តទំនៀមទម្លាប់ វប្បធម៌ និងអត្តសញ្ញាណរបស់ខ្លួន។ |
| **សមភាពយេនឌ័រ** | សមភាពយេនឌ័រគឺជាការឱ្យតម្លៃបុរស និងស្ត្រីឱ្យមានសិទ្ធិស្មើគ្នា ដើម្បីធានាបាននូវភាពយុត្តិធម៌ វិធានការនានាត្រូវបានធ្វើឡើង សម្រាប់ឆ្លើយតបទៅនឹងវិបត្តិនៃប្រវត្តិសាស្ត្រ និងសង្គមដែលធ្លាប់បានរាំងស្ត្រីនិងបុរសមិនឱ្យមានសិទ្ធិស្មើគ្នា។ សមភាពគឺជាមធ្យោបាយ ដើម្បីទទួលបានសមភាពយេនឌ័រ។<br>*ក្របខណ្ឌនៃការអនុវត្តការបញ្ជ្រាបយេនឌ័រ យូណេស្កូ ឆ្នាំ២០០៣* |
| **ការអប់រំបរិយាបន្ន** | "អនុសញ្ញាអង្គការយូណេស្កូ ប្រឆាំងនឹងការរើសអើងក្នុងវិស័យអប់រំ (១៩៦០) ...ហាមឃាត់រាល់ទម្រង់នៃអំពើផាត់ចេញពីសង្គម ការដាក់កម្រិតលើឱកាសសិក្សា ដោយផ្អែកលើភាពខុសគ្នានៃសង្គម ឬការគិតខុសគ្នាដូចជា ភេទ ជនជាតិ សង្គម ភាសា សាសនា សញ្ជាតិ ស្ថានភាពសេដ្ឋកិច្ច និងសមត្ថភាព"។ https://en.unesco.org/themes/inclusion-in-education |

| | |
|---|---|
| **ជនជាតិដើមភាគតិច** | ក្រុមនិងសហគមន៍ភាគច្រើនរស់នៅតំបន់ភ្នំ និងខ្ពង់រាបនៃប្រទេសកម្ពុជា ដែលមានអត្តសញ្ញាណ វប្បធម៌ ភាសា និងសាសនា ខុសគ្នាពីសង្គមខ្មែរ ហើយមានការដឹកនាំ និងមានរបៀបរស់នៅបែបពាក់កណ្តាលផ្សងព្រេង ដោយសារទង្វើនៃ "ការកាប់ និងដុតព្រៃឈើ" ឬការធ្វើកសិកម្មវិលជុំ។ |
| **ប្រព័ន្ធអយ្យកោ** | ប្រព័ន្ធសង្គមមួយដែលបុរសមានអំណាច និងត្រួតត្រា ក្នុងតួនាទីជាអ្នកដឹកនាំនយោបាយ និងមានឯកសិទ្ធិ។ នៅក្នុងប្រព័ន្ធអយ្យកោស្ត្រីត្រូវបានគេដកចេញពីមុខតំណែងនៃអំណាច ហើយត្រូវបានគេរំពឹងថា ឱ្យផ្តោតលើកិច្ចការផ្ទះ គ្រួសារ និងការចិញ្ចឹមកូន។ |
| **ការផាត់ចេញពីសង្គម និងការវិភាគយេនឌ័រ (SEGA)** | សំដៅលើការផាត់ចេញពីសង្គម និងការវិភាគយេនឌ័រ។ SEGA អាចប្រើដើម្បីកំណត់មូលហេតុគ្រឹះនៃបញ្ហាទាក់ទងនឹងការផាត់ចេញពីសង្គមពីការអប់រំ ជាពិសេស ថាតើក្មេងស្រីត្រូវបានគេផាត់ចេញពីប្រព័ន្ធអប់រំយ៉ាងដូចម្តេច? ការវិភាគត្រូវបានអនុវត្ត តាមរយៈការសិក្សាស្រាវជ្រាវប្រតិបត្តិ។ |
| **ទំនោរផ្លូវភេទ** | ការទាក់ទាញខាងផ្លូវភេទរបស់មនុស្សម្នាក់ ចំពោះមនុស្សផ្សេងទៀត។ ទំនោរផ្លូវភេទគឺជាអន្តរកម្មដ៏ស្មុគស្មាញ រវាងការទាក់ទាញខាងផ្លូវភេទ និងអត្តសញ្ញាណខ្លួនឯង។<br>LGBT (QI A) តំណាងឱ្យ:<br>➢ Lesbian: ស្ត្រីដែលស្រឡាញ់លើស្ត្រីដូចគ្នា<br>➢ Gay: បុរសដែលស្រឡាញ់លើបុរសដូចគ្នា<br>➢ Bi: អ្នកដែលស្រឡាញ់ទាំងពីរភេទ គឺជាមនុស្សដែលស្រឡាញ់ទាំងបុរសនិងស្ត្រី។<br>➢ Trans: អ្នកប្តូរភេទ គឺនរណាម្នាក់ ដែលមានអត្តសញ្ញាណភេទខុសពីភេទកំណើតរបស់ខ្លួន។<br>➢ Queer: ជនដែលភាពចម្លែកលើភេទ ជាពាក្យអវិជ្ជមានសម្រាប់ ស្ត្រីដែលស្រឡាញ់លើស្ត្រីដូចគ្នា ឬបុរសដែលស្រឡាញ់លើបុរសដូច។ |

| | |
|---|---|
| | ➢ Intersex: អ្នកដែលមានចរិតផ្លូវភេទដែលពិបាកចាត់ថ្នាក់។<br>➢ Asexual: មនុស្សដែលមិនមានការចាប់អារម្មណ៍ខាងផ្លូវភេទចំពោះបុរសនិងស្ត្រី។ |
| **ការផាត់ចេញពីសង្គម** | "...គឺជាដំណើរការរបស់ក្រុមមនុស្សជាក់លាក់មួយចំនួន ដែលត្រូវបានជួបការលំបាកជាប្រព័ន្ធពីព្រោះត្រូវបានគេរើសអើង ដោយផ្អែកលើជាតិភាគតិច ជាតិសាសន៍ សាសនា ទំនោរផ្លូវភេទ វណ្ណៈ ពូជសាសន៍ យេនឌ័រ អាយុ ពិការភាព មេរោគអេដស៍ ជនចំណាកស្រុក ឬទីកន្លែងដែលពួកគេរស់នៅ។ ការរើសអើងកើតឡើងនៅក្នុងស្ថាប័នសាធារណៈដូចជាប្រព័ន្ធច្បាប់ ឬការអប់រំ និងសេវាសុខភាព ក៏ដូចជាសង្គម និងក្នុងគ្រួសារដែរ"។<br>ឯកសារគោលនយោបាយ DFID (២០០៥) កាត់បន្ថយភាពក្រីក្រ ដោយដោះស្រាយការបដិសេធសង្គម នាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិចក្រភពអង់គ្លេស។ |

# ជំពូក ១ សេចក្តីផ្តើម

## ១.១- ការអប់រំបរិយាបន្ន: ការប្តេជ្ញាចិត្តជាសកលនិងសម្រាប់កម្ពុជា

ប្រទេសកម្ពុជាមិនមែនជាប្រទេសដែលប្រឈមនឹងបញ្ហាអត្រាបោះបង់ការសិក្សាខ្ពស់ អត្រាចុះឈ្មោះចូលរៀនទាប លទ្ធផលសិក្សាទាប នៅតាមសាលារៀនជាច្រើន ហើយត្រូវស្វែងរកដំណោះស្រាយទៅលើបញ្ហាអាកប្បកិរិយា និងពិការភាពរបស់សិស្សតែឯងនោះទេ។ បញ្ហាទាំងនេះកើតឡើងនៅក្នុងសាលារៀន នៅជុំវិញពិភពលោក រួមទាំងប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍។

ជាដំណោះស្រាយចំពោះហេតុការណ៍នេះ និងជំរុញចក្ខុវិស័យរួមមួយដើម្បី "ការផ្លាស់ប្តូរជីវិតតាមរយៈការអប់រំ" វេទិកាអប់រំពិភពលោកឆ្នាំ២០១៥ នៅទីក្រុងអ៊ិនឈុនសាធារណរដ្ឋកូរ៉េ បានអនុម័តសេចក្តីប្រកាសអ៊ិនឈុនសម្រាប់ការអប់រំឆ្នាំ២០៣០[១]។ សេចក្តីប្រកាសនេះ ត្រូវបានប្តេជ្ញាដោយប្រទេសដែលចូលរួម រួមទាំងប្រទេសកម្ពុជាផងដែរ ក្នុងការដោះស្រាយបញ្ហានៃការផាត់ចេញពីសង្គម និងការទទួលបានឱកាសអប់រំសម្រាប់កុមារ ដើម្បីឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ (SDG-4) ឆ្នាំ២០៣០។ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ខិតខំដើម្បី៖

> *"ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងការលើកកម្ពស់ឱកាសក្នុងសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា"* ។

ដើម្បីឱ្យសម្រេចបានចក្ខុវិស័យនេះ ភាគីពាក់ព័ន្ធក្នុងវិស័យអប់រំនៅកម្ពុជា គួរយល់ច្បាស់ពីការផាត់ចេញពីសង្គម និងផលប៉ះពាល់ដល់ការទទួលបានការអប់រំរបស់កុមារ ដើម្បីកសាងប្រព័ន្ធអប់រំបរិយាបន្នមួយ។ ភាគីពាក់ព័ន្ធក្នុងវិស័យអប់រំទាំងអស់ត្រូវយល់ដឹងពីការកំណត់នូវកុមារ ដែលមានហានិភ័យ និងការធ្វើការរួមគ្នា ដើម្បីឈានទៅរកការលុបបំបាត់នូវការផាត់ចេញពីសង្គមក្នុងការអប់រំចាប់ពីមត្តេយ្យសិក្សា រហូតដល់ឧត្តមសិក្សា។ ប្រសិនបើ ភាគីពាក់ព័ន្ធនៅតែមិនយល់ពីឥទ្ធិពលនៃការផាត់ចេញពីសង្គមដែលធ្វើឱ្យមានប៉ះពាល់លើសង្គមនោះទេ វានឹងនៅតែបន្តកើតមាននូវអត្រាបោះបង់ការសិក្សា អត្រាត្រួតថ្នាក់ ការចុះឈ្មោះចូលរៀនទាប និងបញ្ហាអវត្តមានជាដើម ហើយកុមារនៅតែត្រូវបានគេបដិសេធសិទ្ធិទទួលបាន *"ការអប់រំ...ដោយផ្អែកលើមូលដ្ឋានគ្រឹះនៃឱកាសស្មើគ្នា..."* ដូចដែលមានចែងនៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពី សិទ្ធិកុមារ មាត្រា២៨។ ប្រសិនបើ កុមារមិនទទួលបានសិទ្ធិក្នុង *"ការអប់រំប្រកបដោយគុណភាព និងស្មើភាពគ្នា"* នោះទេ នោះគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ នឹងពិបាកសម្រេចបាន។

កាលពីខែកុម្ភៈ ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ពីសារៈសំខាន់នៃ *"គុណភាពអប់រំប្រកបដោយសមធម៌ និងបរិយាបន្ន"* និងបានដាក់ចេញនូវផែនទីបង្ហាញផ្លូវអប់រំឆ្នាំ២០៣០ [២] ដែលស្របទៅនឹងសេចក្តីប្រកាសអ៊ិនឈុន និងតំណាងឱ្យសេចក្តីណែនាំសម្រាប់ប្រទេសកម្ពុជា ដើម្បីក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ លើសពីនេះ ក្រសួងអប់រំ យុវជន និងកីឡា តាមរយៈផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ខ្លួនបាន និងកំពុងបន្តធ្វើការឆ្ពោះទៅរកការធានាឱ្យកុមារ និងយុវជនកម្ពុជាទាំងអស់ទទួលបានឱកាសស្មើគ្នាក្នុងការអប់រំប្រកបដោយគុណភាព ស្របទៅនឹងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះអនុសញ្ញាអង្គការសហប្រជាជាតិស្តីពី សិទ្ធិកុមារ[៣]។ ដើម្បីកែលម្អលទ្ធផលសិក្សារបស់សិស្សគ្រប់រូប ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវគោលនយោបាយចំនួនពីរ៖

*១) ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា*
*២) ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់*

នៅឆ្នាំ២០១៨ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវគោលនយោបាយស្តីពី ការអប់រំបរិយាបន្ន (PIE) ដែលគ្របដណ្តប់លើការផ្តល់ការអប់រំសម្រាប់សិស្ស ដែលងាយរងគ្រោះ និងត្រូវផាត់ចេញពីសង្គម ចាប់ពីកម្រិតមត្តេយ្យសិក្សា រហូតដល់កម្រិតឧត្តមសិក្សា សម្រាប់គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន(MoEYS, 2018)។

## ១.២- បញ្ហាប្រឈមនៃការអប់រំបរិយាបន្ន

ការសម្រេចបេសកកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា លើការអប់រំបរិយាបន្ន គឺជាបញ្ហាប្រឈមដ៏ធំមួយចំពោះបរិបទនៃការផាត់ចេញពីសង្គម និងការដាក់បញ្ចូលទៅក្នុងសង្គម ពីព្រោះវាជាទស្សនៈថ្មីសម្រាប់ប្រទេសកម្ពុជា។ នេះត្រូវបានឆ្លុះបញ្ចាំងពីកង្វះខាតការឈ្វេងយល់ទៅលើការប្រើពាក្យខ្មែរដើម្បីពិពណ៌នាអំពីអត្ថន័យរបស់ពាក្យបរិយាបន្ន។ ដូច្នេះ វាពិបាកក្នុងការភ្ជាប់អត្ថន័យនៃគំនិតនេះឱ្យបានច្បាស់ណាស់ ជាពិសេស អ្នកមិនដែលមានបទពិសោធក្នុងការងារផាត់ចេញពីសង្គម។ ជារួម ការអភិវឌ្ឍការយល់ដឹងរួមគ្នានូវអត្ថន័យនៃពាក្យ និងគំនិត ដែលពាក់ព័ន្ធនឹងការផាត់ចេញពីសង្គម ឬការដាក់បញ្ចូលក្នុងសង្គម ពិតជាមានសារៈសំខាន់ ដើម្បីលើកកម្ពស់ការយល់ដឹងដល់ភាគីពាក់ព័ន្ធក្នុងវិស័យអប់រំនៅគ្រប់កម្រិត។

ជាក់ស្តែង ការយល់ឃើញទាក់ទងទៅនឹងការផាត់ចេញពីសង្គមនៅមានកម្រិត ដោយសារថា គំនិតនៃការអប់រំបរិយាបន្នត្រូវបានណែនាំមកដល់ប្រទេសកម្ពុជា បន្ទាប់ពីវេទិកាអប់រំពិភពលោក “ការអប់រំសម្រាប់ទាំងអស់គ្នា” កាលពីឆ្នាំ២០០០ នៅទីក្រុងដាកា ប្រទេសសេណេហ្គាល់៖

> *"...នៅក្នុងបរិបទ ដែលមានសាលាអប់រំពិសេសតិចតួច មិនមានហេដ្ឋារចនាសម្ព័ន្ធ សម្រាប់ការបណ្តុះបណ្តាល ឬសម្ភារៈសម្រាប់គ្រូអប់រំចំណេះទូទៅ ចំនួននៃបុគ្គលិក ជំនាញ ដែលអាចបំពេញការងារតាមតម្រូវការរបស់សិស្សពិការ នៅមានកម្រិតទាំង ក្នុងសាលាអប់រំពិសេស និងសាលាចំណេះទូទៅ ក៏ដូចជា ការយល់ឃើញថា ការបាន ចូលរៀននៅក្នុងសាលារៀនណាមួយ ប្រសើរជាងការមិនបានចូលរៀន"* ។[៤]

ទោះបី មានឧបសគ្គបែបនេះក៏ដោយ ប្រទេសកម្ពុជាក៏មានការរីកចម្រើនល្អក្នុងការអប់រំកុមារ របស់ខ្លួន។ ចាប់តាំងពីឆ្នាំ២០០៧ ចំនួនកុមារដែលបានចុះឈ្មោះចូលរៀននៅក្នុងមត្តេយ្យសិក្សាមាន ច្រើនជាងទ្វេដង ហើយចំនួនកុមារដែលបានចុះឈ្មោះចូលរៀនបឋមសិក្សានៅឆ្នាំ២០១៨ មានចំនួន រហូតដល់ជាង៩៧ ភាគរយ។ ទោះបីជាយ៉ាងណា កុមារ និងយុវជននៅប្រទេសកម្ពុជា នៅតែមិនទាន់ ឈានដល់កំរិតស្តង់ដានៃការសិក្សា ដែលសមស្របទៅនឹងអាយុរបស់ពួកគេ ដោយសារកត្តាលើក លែងមួយចំនួន។ ការផាត់ចេញពីសង្គមនៃការចូលរៀននៅអនុវិទ្យាល័យនៅតែបង្ហាញពីវិសមភាព តាមរយៈ យេនឌ័រ ភូមិសាស្ត្រ និងក្រុមសេដ្ឋកិច្ចសង្គម ហើយក្មេងស្រី និងក្មេងប្រុសមួយចំនួនធំនៅ តែមិនទាន់បានចូលរៀននៅគ្រប់កម្រិតសិក្សា។ អ្វីដែលគួរឱ្យព្រួយបារម្ភនោះគឺកុមារជាច្រើននៅតែ បោះបង់ការសិក្សាមុនពេលបញ្ចប់ការអប់រំមូលដ្ឋាន។

# ជំពូក ២ ឈ្វេងយល់ពីការផាត់ចេញពីសង្គមនៅកម្ពុជា

## ២.១- និយមន័យ

មនុស្សជាច្រើនជឿថា ផលប៉ះពាល់នៃការផាត់ចេញពីសង្គមត្រូវបានបង្ហាញឱ្យឃើញតាមរយៈជនមានពិការភាពខាងរាងកាយ ឬនៅកន្លែង ដែលមានបញ្ហាទាក់ទងនឹងយេនឌ័រ។ ទោះយ៉ាងណាពាក្យនេះមានលក្ខណៈទូលំទូលាយ និងគ្របដណ្តប់លើផ្នែកជាច្រើន ដែលមនុស្សអាចត្រូវបានគេផាត់ចេញពីសង្គម និងជួបបញ្ហាការរើសអើងផ្សេងៗ។ និយមន័យនៃពាក្យ ការផាត់ចេញពីសង្គម គឺជា៖

*“...ដំណើរការដែលក្រុមណាមួយបានជួបវិបត្តិជាប្រព័ន្ធ ដោយពួកគេត្រូវបានរើសអើងតាមរយៈជាតិសាសន៍ ពូជសាសន៍ សាសនា ទំនៀមទម្លាប់ ភេទ វណ្ណៈ ដើមកំណើត យេនឌ័រ អាយុ ពិការភាព ស្ថានភាពជាអ្នកជំងឺអេដស៍ ស្ថានភាពជាជនចំណាកស្រុក ឬទីកន្លែងដែលពួកគេរស់នៅ។ ការរើសអើងអាចកើតឡើងនៅក្នុងស្ថាប័នសាធារណៈ ដូចជា ក្នុងប្រព័ន្ធច្បាប់ ឬការអប់រំ និងសេវាសុខភាព ព្រមទាំងសង្គមគ្រួសារជាដើម”*។ [៥]

និយមន័យនេះបង្ហាញយ៉ាងច្បាស់ថា មនុស្ស(បុគ្គល ឬក្រុម) អាចត្រូវបានគេផាត់ចេញពីសង្គម និងប្រឈមទៅនឹងការរើសអើង ដោយសារតែកត្តាផ្សេងៗ។ ការផាត់ចេញពីសង្គមអាចកើតមានដោយសារកត្តាពីរ ឬច្រើន កើតមានឡើងព្រមគ្នាដូចជា៖ យេនឌ័រ ពិការភាព និងភាពក្រីក្រ ឬទំនោរផ្លូវភេទ និងជំងឺអេដស៍។ ការផាត់ចេញពីសង្គមផ្តោតទាំងកត្តាសង្គម នយោបាយ វប្បធម៌ និងសេដ្ឋកិច្ច រួមទាំងឥទ្ធិពលនៃការទំនាក់ទំនងមិនស្មើភាពគ្នា។ បុគ្គល និងក្រុមដែលទទួលរងការផាត់ចេញពីសង្គម ច្រើនតែមានជីវភាពក្រីក្រ ទោះបីជា ភាពក្រីក្រតែមួយមុខ មិនត្រូវបានគេផាត់ចេញពីសង្គមក៏ដោយ ពីព្រោះ វាមានទស្សនៈយល់ឃើញ ខុសគ្នារវាងភាពក្រីក្រ និងការផាត់ចេញពីសង្គម។ ទោះបីយ៉ាងណា ភាពក្រីក្រត្រូវបានគេកត់សម្គាល់ ឃើញថាជាកត្តាមួយ ដែលនាំឱ្យមានការផាត់ចេញពីសង្គម។ ការផាត់ចេញពីសង្គម និងការរើសអើងក្នុងសង្គម នាំឱ្យមិនមានការគោរពសិទ្ធិមនុស្ស រាំងស្ទះដល់ការកាត់បន្ថយភាពក្រីក្រ និងជះឥទ្ធិពលអវិជ្ជមានក្នុងការអភិវឌ្ឍ និងកំណើនសេដ្ឋកិច្ច។




រូបភាពទី១ វិមាត្រនៃការផាត់ចេញពីសង្គម

ការផាត់ចេញពីសង្គមជានិច្ចកាល កើតឡើងដោយអចេតនា ដូចជា ជនមានពិការភាពត្រូវបានគេផាត់ចេញដោយសារ កង្វះការយល់ដឹងពីតម្រូវការរបស់ពួកគេ ឬក្រុមជនជាតិដើមភាគតិចត្រូវបានគេផាត់ចេញដោយសារ កង្វះភាសាទំនាក់ទំនងរួមគ្នា។ ទោះបីយ៉ាងណាក៏ដោយ អារម្មណ៍នៃភាពគ្មានអំណាច អាចធ្វើឱ្យថមថយសេចក្តីប្រាថ្នារបស់ពួកគេ ជាពិសេស នៅពេលមានការបង្ហាញឥរិយាបថរើសអើងច្បាស់លាស់។ ក្នុងគន្លងបែបនេះ បុគ្គល ឬក្រុមដែលត្រូវបានគេផាត់ចេញពីសង្គម បានធ្វើឱ្យប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងឱ្យរួចផុតពីភាពក្រីក្ររបស់ខ្លួន។

## ២.២- ការផាត់ចេញពីសង្គមក្នុងវិស័យអប់រំ

និយមន័យនៃការផាត់ចេញពីសង្គមដែលបានផ្តល់ឱ្យខាងលើជា ឧទាហរណ៍នៃការផាត់ចេញពីសង្គមទូទៅ ដែលកើតឡើងតាមរយៈកត្តាផ្សេងៗគ្នា។ ទោះបីជាយ៉ាងណាក៏ដោយ ការលើកឡើងទាំងអស់នេះ មិនមែនពាក់ព័ន្ធទៅនឹងគ្រប់បរិបទនោះទេ ហើយក៏មិនទាក់ទងទៅនឹងការផាត់ចេញពីសង្គមរបស់កុមារពីប្រព័ន្ធអប់រំដែរ។ កត្តាទាំងនោះធ្វើឱ្យប៉ះពាល់ដល់ការយល់ដឹងនៃការអប់រំបរិយាបន្ន។ ខាងក្រោមនេះ ជាបទពិសោធទូទៅនៅតាមសាលារៀន ក្នុងប្រទេសកម្ពុជា។

### ២.២.១- ពិការភាព

ដោយសារតែសង្គ្រាមអន្តរជាតិ និងសង្គ្រាមស៊ីវិលជាច្រើនទសវត្សរ៍ ដែលបណ្តាលឱ្យមានគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះដ៏ច្រើនសន្ធឹកសន្ធាប់ បន្សល់ទុកនៅក្នុងប្រទេសកម្ពុជា បានធ្វើឱ្យមានជនមានពិការភាពខ្ពស់ជាងគេនៅទូទាំងពិភពលោក។ បន្ទាប់ពីសង្គ្រាមរ៉ាំរ៉ៃបានបញ្ចប់ ការស្តារនីតិសម្បទា និងសេវាអប់រំសម្រាប់កុមារពិការត្រូវបានចាត់ទុកជាកត្តាសំខាន់ពីសំណាក់រាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល។

ទោះបីជា អត្រាចុះឈ្មោះចូលរៀនមានការកើនឡើង គួរឱ្យកត់សម្គាល់ក៏ដោយ កុមារមានពិការភាពភាគច្រើនមិនបានចុះឈ្មោះចូលរៀន ឬក៏បោះបង់ការសិក្សា។ នៅឆ្នាំ២០១៩ ចំនួនសិស្សមានពិការភាព នៅសាលាបឋមសិក្សា សរុបមានប្រមាណ ៤៥.០០០នាក់ និងប្រហែល ៧.០០០នាក់ នៅអនុវិទ្យាល័យក្នុងប្រទេសកម្ពុជា [៧]។

ជារឿយៗ កុមារដែលមានពិការភាពត្រូវបានគេផាត់ចេញពីទិដ្ឋភាពនៃការរស់នៅដោយសារតែ កង្វះការធ្វើចលនា ផ្នែករាងកាយ ចក្ខុខ្សោយ ឬគថ្លង់ ហើយជួនកាល ដោយសារតែ ការមិនយល់ដឹងពី តម្រូវការរបស់ពួកគេ។ សាលារៀនភាគច្រើននៅ ក្នុងប្រទេសកម្ពុជាមិនបានផ្តល់ភាពងាយស្រួលដល់ កុមារមានពិការភាពផ្នែករាងកាយ ដោយសារតែ កង្វះហេដ្ឋារចនាសម្ព័ន្ធ ដើម្បីបំពេញតម្រូវការរបស់ ពួកគេដូចជា ផ្លូវជម្រាល បង្គន់អនាម័យ និងកន្លែងលាងដៃ។ កុមារដែលមានបញ្ហាបំលាស់ទីក៏ជួបការ លំបាកក្នុងការរកមធ្យោបាយធ្វើដំណើរទៅសាលារៀនផងដែរ។

លើសពីនេះទៀត កុមារមានពិការភាពផ្នែករាងកាយជារឿយៗ ប្រឈមនឹងការរើសអើងក្នុង សង្គមពីសំណាក់គ្រូបង្រៀន និងសិស្សផងដែរ។ នៅពេលដែលនៅសាលារៀនពួកគេតែងតែត្រូវបានគេ ធ្វើបាប។ គ្រូបង្រៀនជាច្រើនមិនបានទទួលការបណ្តុះ បណ្តាលក្នុងការធ្វើការជាមួយសិស្ស ដែលមាន ពិការភាពនោះទេ ដូច្នេះ ពួកគាត់មិនដឹងពីវិធីសាស្ត្របង្រៀនកុមារដែលមានពិការភាព ប្រកបដោយ ប្រសិទ្ធភាពបានទេ។ បញ្ហានេះកាន់តែធ្ងន់ធ្ងរបន្ថែមទៀត នៅពេលដែលពិការភាពរបស់កុមារត្រូវបាន គេឱ្យតម្លៃទាប និងមានការយល់ដឹងតិច ឧទាហរណ៍ ពិការភាពផ្នែកសតិបញ្ញា ពិបាកបញ្ចេញសម្លេង ក្នុងការអាន និងបញ្ហាផ្លូវចិត្តកើតឡើង ដោយសារការភ័យខ្លាច។ ប្រសិនបើ សាលារៀនមិនអាចដោះ ស្រាយតម្រូវការរបស់សិស្ស ដែលមានពិការភាព ហើយគ្រូបង្រៀននៅតែបង្ហាញទង្វើរើសអើង វានឹងធ្វើ ឱ្យសិស្សទាំងនេះមានអារម្មណ៍ថា ពួកគេត្រូវបានផាត់ចេញពីសង្គម ហើយទីបំផុតនឹងត្រូវបោះបង់ចោល ការសិក្សា ។

## ២.២.២- ក្រុមជនជាតិដើមភាគតិច

មានក្រុមជនជាតិដើមភាគតិចប្រមាណ២៤ ក្រុមខុសៗគ្នា មានចំនួនប្រហែលជា១ ទៅ២ភាគ រយនៃប្រជាជន ដែលរស់នៅក្នុងប្រទេសកម្ពុជា។ ភាគច្រើននៃក្រុមទាំងនេះមានទីតាំងនៅខេត្តរតនគីរី និងមណ្ឌលគីរី ហើយក្រុមផ្សេងៗទៀត រស់នៅក្នុងខេត្តចំនួន១៣ ទៀត (វិទ្យាស្ថានជាតិស្ថិតិ) រួម មាន៖ ខេត្តស្ទឹងត្រែង ក្រចេះ ព្រះវិហារ កំពង់ធំ កោះកុង ពោធិសាត់ កំពង់ស្ពឺ ព្រះសីហនុ ខេត្តបន្ទាយ មានជ័យ បាត់ដំបង កំពង់ចាម ឧត្តរមានជ័យ និងសៀមរាប។ ក្រុមជនជាតិដើមភាគតិច មានវប្បធម៌ ខុសគ្នា ទោះបីជា ក្រុមខ្លះមានទំនៀមទម្លាប់ និងជំនឿស្រដៀងគ្នាក៏ដោយ ហើយភាគច្រើននៃជន ជាតិដើមភាគតិច ដែលមានវ័យចំណាស់ មិនចេះអក្សរ និងមិនចេះនិយាយភាសាខ្មែរនោះទេ។

បញ្ហាប្រឈមចម្បងរបស់ក្រុមជនជាតិដើមភាគតិច គឺសុខុមាលភាពផ្នែករាងកាយ ដោយសារ ស្ថានភាពសុខភាពរបស់ពួកគេមានភាពទន់ខ្សោយជាងប្រជាជនកម្ពុជាដទៃទៀត ហើយពួកគេផ្លាស់ ប្តូរការដាំដុះ និងពឹងផ្អែកលើកសិផលព្រៃឈើសម្រាប់ជីវភាពរស់នៅ។

ការរិចរិលនៃបរិស្ថាន និងការរំលោភយកដីធ្លីបានកើនឡើង ដែលធ្វើឱ្យមានការថយចុះនូវដីសម្រាប់ប្រើប្រាស់ធ្វើកសិកម្មរបស់ពួកគេ ដែលបណ្តាលឱ្យមានការខ្វះស្បៀងអាហារ ដូច្នេះ កុមារមួយចំនួនធំទទួលរងផលប៉ះពាល់ធ្វើឱ្យមានភាពក្រិន(ការថយចុះការលូតលាស់ និងការអភិវឌ្ឍ)។ កង្វះអនាម័យមូលដ្ឋាន នៅតាមសហគមន៍របស់ពួកគេមួយចំនួនបានបង្កើនហានិភ័យ ដែលធ្វើឱ្យកុមារមានជំងឺរាគរុស និងជំងឺប៉ារ៉ាស៊ីត[៨]។ កង្វះអាហារូបត្ថម្ភ ការឆ្លងប៉ារ៉ាស៊ីត និងភាពក្រិនមានទំនាក់ទំនងជាមួយនឹងភាពមានសតិបញ្ញាខ្សោយ។[៨]

កុមារជនជាតិដើមភាគតិចជាច្រើន ដែលរស់នៅតំបន់ដាច់ស្រយាល ត្រូវធ្វើដំណើរផ្លូវឆ្ងាយដើម្បីទៅសាលារៀន ហើយការធ្វើដំណើរផ្លូវឆ្ងាយដោយឆ្លងកាត់តំបន់ដាច់ស្រយាលគឺមិនមានសុវត្ថិភាពសម្រាប់ក្មេងស្រីទេ។ បញ្ហានៃការដឹកជញ្ជូនមានការលំបាកនៅរដូវវស្សា ពីព្រោះផ្លូវថ្នល់ត្រូវបានជន់លិចជាញឹកញាប់ដែលមិនអាចឆ្លងកាត់បាន ហើយបញ្ហាប្រឈមផ្សេងទៀតគឺកង្វះសាលារៀន ដែលផ្តល់ការអប់រំមិនលើសកម្រិតថ្នាក់ទី៣ សម្រាប់ការរៀនភាសាកំណើតរបស់ពួកគេ។ ដូច្នេះ កុមារដែលគ្រប់អាយុចូលរៀននៃក្រុមជនជាតិដើមភាគតិច ប្រឈមទៅនឹងការទទួលបានការអប់រំទាប ហើយធ្វើឱ្យមានអត្រាបោះបង់ការសិក្សាខ្ពស់ និងកាត់បន្ថយឱកាសទទួលបានការងារធ្វើរយៈពេលវែង[៩]។ នៅពេលដែលមិនអាចបំពេញតម្រូវការរបស់ពួកគេបានគ្រប់គ្រាន់ និងលទ្ធផលនៃការសិក្សានៅតែស្ថិតក្រោមការរំពឹងទុក កុមារទាំងនេះទំនងជាមិនអាចបញ្ចប់ការអប់រំកម្រិតមូលដ្ឋានបាននោះទេ។

## ២.២.៣- សមភាពយេនឌ័រ

ខណៈពេលដែលរាជរដ្ឋាភិបាលបន្តលើកកម្ពស់សមភាពយេនឌ័រ ក្នុងគោលនយោបាយនិងផែនការរបស់ខ្លួន ការរើសអើងទៅនឹងក្មេងស្រីនិងស្ត្រី នៅតែកើតមានខ្លះៗនៅក្នុងប្រទេសកម្ពុជា តាមលក្ខណៈប្រពៃណីសង្គមកម្ពុជា ដែលតែងឱ្យតម្លៃបុរសជាងស្ត្រី។ ម្យ៉ាងវិញទៀត ស្ត្រីត្រូវបានគេផ្តោតលើអាកប្បកិរិយា និងកិត្តិយស ជាជាងលើកកម្ពស់ការអប់រំល្អ ឬទទួលបានជោគជ័យក្នុងអាជីវកម្ម[៩] ហើយត្រូវបានគេឱ្យនៅធ្វើកិច្ចការផ្ទះ និងមើលថែកូនៗ ចំណែកប្តីចេញទៅធ្វើការខាងក្រៅ។

នៅពេលដែលរាជរដ្ឋាភិបាលកម្ពុជាបន្តលើកកម្ពស់សមភាពយេនឌ័រ ក្នុងគោលនយោបាយ និងផែនការការពារនៃការរើសអើងស្ត្រី ដែលកើតមានឡើងនៅក្នុងតំបន់ ជាច្រើនទូទាំងសង្គមកម្ពុជា។ បញ្ហាទាំងនេះកើតឡើងមកពីទំនៀមទំលាប់ និងប្រពៃណីរបស់ប្រជាជនដែលគាំទ្រគំនិតថា ស្ត្រីស្ថិតនៅក្រោមការការពាររបស់ស្វាមីនិងត្រូវបានគេរំពឹងថា ស្ត្រីជួយសម្រាលបន្ទុកស្វាមីដោយត្រូវធ្វើការងារផ្ទះ។

គេចាត់ទុកថា អំពើហិង្សាក្នុងគ្រួសារជារឿងធម្មតា ហើយទុកឱ្យក្រុមគ្រួសារគួរជាអ្នកដោះស្រាយជាជាងដោះស្រាយតាមប្រព័ន្ធតុលាការ។ ទោះបីជា ការលែងលះជាដំណើរការស្របច្បាប់សម្រាប់ប្រទេសកម្ពុជា ប៉ុន្តែ ការខ្វះខាតភ្នាក់ងារជួយសម្របសម្រួលដំណើរការផ្លូវច្បាប់ បានធ្វើឱ្យស្ត្រីត្រូវបង្ខំចិត្តរស់នៅជាមួយស្វាមីដែលខ្លួនមិនពេញចិត្ត ដើម្បីចិញ្ចឹមបីបាច់ថែរក្សាកូន[១០]។

បែបបទយេនឌ័រអេយ្យកោមាននៅក្នុងប្រព័ន្ធអប់រំតាំងពីយូរមកហើយ។ នៅក្នុងសាលារៀន អាកប្បកិរិយាជាទម្លាប់របស់បុរស មានឥទ្ធិពលលើការប្រើ *"អំពើហឹង្សា ការរំលោភបំពាន ការយាយីផ្លូវភេទ និងសកម្មភាពផ្លូវភេទដោយបង្ខំ"*[១១]។ អាកប្បកិរិយាទាំងនេះនាំឱ្យសិស្សស្រីទទួលបានលទ្ធផលសិក្សាខ្សោយ និងបង្ហាញការមិនឱ្យតម្លៃខ្លួនឯង។ សៀវភៅសិក្សា ដែលត្រូវបានប្រើនៅក្នុងសាលារៀននៅប្រទេសកម្ពុជាក៏បង្ហាញពីការរើសអើងយេនឌ័រក្នុងការបង្ហាញ *"បុរសជាវេជ្ជបណ្ឌិត មេធាវី វិស្វករ និងអ្នកគ្រប់គ្រង និងស្ត្រីជាអ្នកទទួលភ្ញៀវ អ្នកតម្បាញ អ្នកថែរក្សាផ្ទះ កសិករ និងជំនួយការហាង"* [១២]។

ហេដ្ឋារចនាសម្ព័ន្ធមិនល្អនៅក្នុងសាលារៀនគឺជាបញ្ហាប្រឈមសម្រាប់សិស្សស្រីដូចជា កង្វះខាតបង្គន់អនាម័យ ឬខ្វះខាតទឹក។ ក្មេងស្រីដែលដល់អាយុមានរដូវ (ជាទូទៅ ចាប់ពីអាយុប្រហែល ១២ឆ្នាំ) មិនអាចទៅសាលារៀនបានទេ ប្រសិនបើ សាលារៀនគ្មានបង្គន់អនាម័យ ដែលផ្តល់សុវត្ថិភាព ក៏ដូចជា ភាពឯកជនដល់ពួកគេ។ កង្វះខាតសម្ភារៈប្រើប្រាស់ បន្ទប់ទឹកស្អាត និងកង្វះសុវត្ថិភាព អាចបណ្តាលឱ្យក្មេងស្រីខកខានមិនបានទៅសាលារៀនជារៀងរាល់ខែ ហើយទីបំផុត ពួកគេបោះបង់ការសិក្សាចោលទាំងស្រុង។

## ២.២.៤- និន្នាការភេទ

នៅប្រទេសកម្ពុជា មិនមានច្បាប់ព្រហ្មទណ្ឌជាក់លាក់ណាមួយប្រឆាំងនឹងការស្រឡាញ់ភេទដូចគ្នាទេ។ ទោះយ៉ាងណាក៏ដោយ ច្បាប់ក៏មិនបានការពារសិទ្ធិជាក់ស្តែងដល់អ្នកស្រឡាញ់ភេទដូចគ្នា ដែរ ព្រោះថា គ្មានច្បាប់ប្រឆាំងនឹងការរើសអើង និងមិនមានការពិន័យចំពោះអ្នក ដែលរើសអើងលើអ្នកស្រលាញ់ភេទដូចគ្នា។ ជាទូទៅ អ្នកស្រឡាញ់ភេទដូចគ្នា មិនត្រូវបានគេប្រកាន់ ដរាបណាពួកគេមិនប្រឆាំងនឹងបទដ្ឋានសង្គម និងវប្បធម៌ [១៣]។

ទោះយ៉ាងណា បើយោងទៅតាមការស្ទង់មតិសហគមន៍ឥន្ទធនូកម្ពុជា ហៅកាត់ថា (RoCK) ក្នុងឆ្នាំ២០១៥[១៤] ការរើសអើងលើនិន្នាការផ្លូវភេទត្រូវបានជួបប្រទះដោយក្រុមអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងទិដ្ឋភាពជាច្រើននៃការរស់នៅរបស់ពួកគេ ដូចជា នៅក្នុងគ្រួសារ កន្លែងធ្វើការ សាលារៀន តាមទីសាធារណៈ និងនៅពេលដែលពួកគេចូលបម្រើសេវាសាធារណៈ។ សមាជិកនៃសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ត្រូវបានគេមិនរាប់រក និងមានភាពឯកោក្នុងសង្គម ក៏ដូចជា សាលារៀន ជាបញ្ហាធំមួយ ដែលពួកគេជួបប្រទះ ដោយសារតែអត្តសញ្ញាណយេនឌ័រ និងទំនោរផ្លូវភេទ។

ដូច្នេះ អត្រាបោះបង់ការសិក្សាក្នុងចំណោមយុវជនស្រលាញ់ភេទដូចគ្នា គឺខ្ពស់ជាងយុវជនទូទៅ ដែលនាំឱ្យពួកគេតែងជួបការលំបាកក្នុងការស្វែងរកការងារធ្វើ និងមានផលប៉ះពាល់ផ្លូវចិត្តរយៈពេលវែង។

## ២.២.៥- ស្ថានភាពជំងឺអេដស៍

នៅឆ្នាំ២០១៩ មានប្រជាជនកម្ពុជាផ្ទុកមេរោគអេដស៍ ប្រមាណ ៧៣.០០០ នាក់ [១៥] ក្នុងនោះ រួមមានកុមារប្រមាណ ៣.០០០ នាក់ផងដែរ។ ចំនួននេះបានបន្តថយចុះ ប៉ុន្តែកុមារដែលរស់នៅជាមួយឪពុកម្តាយ ឬសមាជិកគ្រួសារដែលផ្ទុកមេរោគអេដស៍ នៅតែបន្តទទួលរងការរើសអើងដដែល។ ខណៈពេល ដែលភាគច្រើននៃកុមារមានផ្ទុកមេរោគអេដស៍ ឬកុមារមកពីក្រុមគ្រួសារអ្នកផ្ទុកមេរោគអេដស៍អាចចូលរៀនបាន ជនជាតិភាគតិចមួយចំនួនបាននិយាយថា ពួកគេត្រូវបានផាត់ចេញពីសាលាក្នុងតំបន់របស់ពួកគេ។ មូលហេតុចម្បងក្នុងការផាត់ចេញនេះ គឺបណ្តាលមកពីការមិនយល់ដឹងទាក់ទងនឹងមេរោគអេដស៍ និងការភ័យខ្លាចក្នុងការឆ្លងជំងឺនេះ[១៥]។

## ២.៣- ភាពស្មុគស្មាញនៃការផាត់ចេញពីសង្គម

មានស្ថានភាពជាច្រើន ដែលកុមារអាចត្រូវបានផាត់ចេញពីសង្គមក្នុងប្រព័ន្ធអប់រំទាំងតាមរយៈការមិនយកចិត្តទុកដាក់ ការរស់នៅក្នុងភាពក្រីក្រ ឬដោយចេតនាបុរេវិនិច្ឆ័យ ដោយប្រើអំណាច និងការគ្រប់គ្រង។ ទស្សនៈនៃការអប់រំបរិយាបន្នគឺដើម្បីធានាថា កុមារដែលទទួលរងពីការរើសអើងបែបនេះត្រូវបាននាំចូលមកក្នុងប្រព័ន្ធអប់រំវិញ យ៉ាងហោចណាស់ ពួកគេអាចបញ្ចប់ការអប់រំមូលដ្ឋានបាន។

ឥរិយាបថរើសអើង ត្រូវបានបង្ហាញតាមលក្ខណៈ និងជំនាន់ផ្សេងៗគ្នារបស់មនុស្សនៅក្នុងប្រទេសកម្ពុជា។ យុវជនជំនាន់ក្រោយ ដែលមានជំនាញក្នុងការប្រើប្រាស់បណ្តាញសង្គមទំនងជាបានបង្ហាញពីឥរិយាបថសេរីនិយម និងមានទស្សនៈខុសគ្នាខ្លាំងចំពោះសមាជិកនៃក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ក៏ដូចជា សមភាពយេនឌ័រ បើប្រៀបធៀបនឹងឪពុកម្តាយ និងជីដូនជីតារបស់ពួកគេ។ ទោះយ៉ាងណា ប្រទេសកម្ពុជានៅតែប្រកាន់យកអយ្យកោស្ត្រីយ៉ាងតឹងរឹង និងបទដ្ឋានសង្គម និងឥរិយាបថ វប្បធម៌ដែលមិនងាយផ្លាស់ប្តូរបានឆាប់រហ័សឡើយ សូម្បីតែករណីដែលមានបំណងចង់ធ្វើក៏ដោយ។

គួរកត់សំគាល់ផងដែរថា មានក្រុមជាច្រើន ដែលជ្រើសរើសការដកខ្លួនចេញពីសង្គមដើម្បីការពារវប្បធម៌ និងអត្តសញ្ញាណរបស់ពួកគេ។ នេះជាភស្តុតាងក្នុងករណីក្រុមជនជាតិដើមភាគតិចដែលមិនចង់ធ្វើសមាហរណកម្មទៅក្នុងសង្គមដែលមានឥទ្ធិពល ហើយពួកគេមានអារម្មណ៍ថា រងការគំរាមកំហែងលើវិថីជីវិតរបស់ពួកគេជាបណ្តើរៗ។ នេះមានភាពស្មុគស្មាញក្នុងការផ្សារភ្ជាប់រវាងភាសាវប្បធម៌ អត្តសញ្ញាណ និងកន្លែងដែលកុមារឆ្លងកាត់ ដូចជា ក្នុងសាលារៀន ពួកគេចាំបាច់ត្រូវនិយាយភាសាខ្មែរជាដើម។ ការមានការភ័យខ្លាចថា វប្បធម៌ជនជាតិដើមភាគតិចនឹងរលាយសាបសូន្យ នៅពេលក្មេងៗ ភ្លេចភាសាកំណើតរបស់ខ្លួន និងចាប់យកការរស់នៅបែបថ្មី។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតគោលនយោបាយមួយចំនួន ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់បុគ្គល ដែលត្រូវបានគេផាត់ចេញពីសង្គម ឧទាហរណ៍ ការគាំទ្រដល់ជនពិការ និងអភិវឌ្ឍការគាំទ្រភាសាដើមសម្រាប់កុមារជនជាតិដើមភាគតិច។ ហេតុនេះពួកគេអាចរៀនអាន និងសរសេរជាភាសាកំណើតរបស់ពួកគេបាន។ ទោះយ៉ាងណាក៏ដោយ គោលនយោបាយតែមួយមិនអាចដោះស្រាយតម្រូវការរបស់មនុស្សដែលមានអារម្មណ៍ថាពួកគេត្រូវបានគេផាត់ចេញពីសង្គមនោះទេ ជាពិសេស នៅពេលដែលកត្តាផាត់ចេញពីសង្គមមួយចំនួនត្រូវបានកើតឡើងទន្ទឹមគ្នា។ ហេតុដូច្នេះ ដើម្បីសម្រេចបាននូវការអប់រំបរិយាបន្ន គ្រប់ភាគីពាក់ព័ន្ធត្រូវតែអនុវត្តសកម្មភាពបែបវិជ្ជមានជាចាំបាច់។

# ជំពូក ៣ ការផ្លាស់ប្តូរពីការផាត់ចេញពីសង្គមទៅជាការអប់រំបរិយាបន្ន

ជំពូកនេះនឹងពិនិត្យមើលរបៀប ដែលការផាត់ចេញពីសង្គមអាចដោះស្រាយបាន ហើយត្រូវបានលុបចេញពីប្រព័ន្ធអប់រំក្នុងរយៈពេលវែង។ វានឹងប្រើទស្សនវិស័យផ្សេងៗគ្នា ដើម្បីមើលពីលក្ខណៈដែលការផាត់ចេញពីសង្គមអាចត្រូវបានប្រែក្លាយទៅជាការបរិយាបន្នសង្គម ដើម្បីទទួលបាន “*ការអប់រំប្រកបដោយគុណភាព និងសមធម៌*”។

## ៣.១- គោលនយោបាយស្តីពី ការអប់រំបរិយាបន្ន

សេចក្តីប្រកាសអ៊ិនឈុន និងការអប់រំឆ្នាំ២០៣០ រក្សាជំហរយ៉ាងរឹងមាំទៅលើបរិយាបន្ន និងសមធម៌។ ឯកសារទាំងនេះ បញ្ជាក់ពីតម្រូវការសម្រាប់ការខិតខំប្រឹងប្រែងបន្ថែមក្នុងគោលបំណងដាក់លាក់ចំពោះកុមារ ដែលជួបការលំបាកក្នុងស្ថានភាពងាយរងគ្រោះ “*ប្រជាជនទាំងអស់ដោយមិនគិតពីភេទ អាយុ ពូជសាសន៍ ពណ៌សម្បុរ ជាតិសាសន៍ ភាសា សាសនា នយោបាយ ឬគំនិតផ្សេងទៀត ដើមកំណើតជាតិ សង្គមវប្បធម៌ ទ្រព្យសម្បត្តិ ឬកំណើត ក៏ដូចជាស្ថានភាពជាជនពិការ ជនចំណាកស្រុក ជនជាតិដើមភាគតិច កុមារ និងយុវជន ជាពិសេសអ្នកដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ ឬស្ថានភាពផ្សេងៗទៀត គួរតែមានលទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាព សមធម៌ និងឱកាសសិក្សាពេញមួយជីវិត*”។

ទោះយ៉ាងណា ការអប់រំឆ្នាំ២០៣០ ក៏ទទួលស្គាល់ថា “*គ្រោះថ្នាក់នៃការផ្តោតលើដំណើរនៃការអប់រំ ដែលត្រូវផ្តល់ឱ្យជាសាធារណៈ ដោយមិនយកចិត្តទុកដាក់គ្រប់គ្រាន់ថា តើសិស្សកំពុងសិក្សានិងទទួលបាននូវជំនាញដែលពាក់ព័ន្ធពេលកំពុងរៀនដែរឬទេ*”។ ការអប់រំបរិយាបន្នអាចមានប្រសិទ្ធភាពលុះត្រាតែគ្រូមានការប្តេជ្ញាចិត្ត និងមានជំនាញក្នុងការបង្រៀនសិស្សបែបចម្រុះ។ ដូច្នេះ សាលារៀនត្រូវជួលគ្រូដែលមានការបណ្តុះបណ្តាលល្អ ចេះយល់ចិត្ត និងមានបទពិសោធ ដើម្បីធានាថា គោលដៅ SDG-4 ត្រូវបានបំពេញ។ ក្រសួងអប់រំ យុវជន និងកីឡា មានទំនួលខុសត្រូវក្នុងការធានាបានថា បញ្ហានេះត្រូវបានរៀបចំផែនការដោះស្រាយជាបន្ទាន់។

ជារួម ដើម្បីធានាថា មិនមានកុមារណាម្នាក់ត្រូវបានគេផាត់ចេញពីការអប់រំ សាលារៀនចាំបាច់ត្រូវចែករំលែកការយល់ដឹង និងកំណត់នូវអត្ថន័យនៃការអប់រំប្រកបដោយបរិយាបន្ន ឱ្យបានច្បាស់លាស់។ ការអនុវត្តការអប់រំបរិយាបន្នថ្នាក់រៀន ត្រូវបានអភិវឌ្ឍ ដោយអនុញ្ញាតឱ្យសិស្សមកពីគ្រប់មជ្ឈដ្ឋានទាំងអស់ បានចូលរៀន ហើយសាលារៀនខិតខំប្រឹងប្រែងធ្វើយ៉ាងណា ដើម្បីបង្កើតវប្បធម៌

ចម្រុះក្នុងថ្នាក់រៀន។ ថ្នាក់ដឹកនាំសាលារៀនត្រូវសហការជាមួយលោកគ្រូ អ្នកគ្រូរបស់ខ្លួន ដើម្បីកសាងវប្បធម៌បរិយាបន្ននៅក្នុងថ្នាក់រៀនរបស់ពួកគេ។

គោលបំណងសំខាន់នៃការអប់រំបរិយាបន្ន គឺដើម្បីលុបបំបាត់ការអនុវត្តដែលប្រព្រឹត្តដោយមិនមានការយល់ដឹង និងអាកប្បកិរិយាអវិជ្ជមានចំពោះអ្នកមានពិការភាព យេនឌ័រ ជនជាតិ ជនជាតិដើមភាគតិច អ្នកមានទំនោរផ្លូវភេទ និងអ្នកដែលមានផ្ទុកមេរោគអេដស៍។ សាលារៀនត្រូវពង្រឹងគោលនយោបាយការពារកុមារឱ្យបានទូលំទូលាយ ដោយផ្ដោតលើកុមារងាយរងគ្រោះបំផុតឱ្យផុតពីហានិភ័យនៃអំពើហឹង្សាផ្លូវភេទ អំពើហឹង្សាក្នុងគ្រួសារ ការរំលោភបំពានផ្លូវភេទ និងរាងកាយ ព្រមទាំងពលកម្មដោយបង្ខំ។

## ៣.២- ផែនការសម្រាប់ការអប់រំបរិយាបន្ននៅគ្រប់កម្រិតសិក្សា

ការចែករំលែកចំណេះដឹង ដែលបានកំណត់យ៉ាងច្បាស់នៃការអប់រំបរិយាបន្នត្រូវតែអនុវត្ត។ មន្ត្រីដែលធ្វើការក្នុងវិស័យអប់រំនៅកម្រិតថ្នាក់ជាតិ មន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលខណ្ឌ-ក្រុង-ស្រុក និងសាលារៀន ត្រូវតែកំណត់អត្តសញ្ញាណកុមារងាយប្រឈមនឹងហានិភ័យនៃការផាត់ចេញពីសង្គម និងធានាថា បទអន្តរាគមន៍ត្រូវបានបង្កើតឡើង ដើម្បីការពារកុមារងាយរងគ្រោះទាំងនោះពីការបោះបង់ការសិក្សាជាពិសេស គឺកម្រិតអប់រំថ្នាក់មូលដ្ឋាន។ ការផ្ដល់មូលនិធិដល់បទអន្តរាគមន៍ទាំងនេះ មិនថា ថវិការាជរដ្ឋាភិបាលក្ដី ឬថវិកាដែលផ្ដល់ដោយដៃគូអភិវឌ្ឍនិងអង្គការមិនមែនរដ្ឋាភិបាលក្ដី គឺត្រូវតែដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) និងផែនការប្រតិបត្តិការប្រចាំឆ្នាំ(AOP) ដែលជាសកម្មភាពបានគ្រោងទុកមុន។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់ជាតិឆ្នាំ២០១៩-២០២៣ បានបង្កើតយន្តការសម្រាប់បញ្ហានេះរួចហើយជាមួយនឹងគោលនយោបាយទី១ របស់ខ្លួន៖

> ១) *ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។*

ទោះយ៉ាងណាក៏ដោយ ដូចដែលបានបញ្ជាក់ខាងលើ ដើម្បីឱ្យមានការផ្លាស់ប្ដូរកើតឡើង បញ្ហាពាក់ព័ន្ធទាំងអស់ត្រូវតែអនុវត្តតាមផែនការសកម្មភាពជាចាំបាច់ ដូច្នេះគឺជាទំនួលខុសត្រូវរបស់អ្នករៀបចំផែនការ ដើម្បីដាក់បញ្ចូល និងបង្កើតសកម្មភាពនៅក្នុងផែនការរបស់ខ្លួន ដើម្បីលុបបំបាត់ការផាត់ចេញពីសង្គម និងនាំឱ្យមានការអនុវត្តការអប់រំបរិយាបន្នបន្ថែមទៀតក្នុងសាលារៀនរបស់ពួកគេ។

### ៣.២.១- ការវិភាគការផាត់ចេញពីសង្គម និងយេនឌ័រ (SEGA)

ដើម្បីដឹងថា កត្តាលើកលែងអ្វីខ្លះ ដែលជះឥទ្ធិពលដល់សិស្សនៅក្នុងសាលារៀន ការសង្កេតចាំបាច់ត្រូវធ្វើដោយមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា

នៃរដ្ឋបាលខណ្ឌ-ក្រុង-ស្រុក ឬសាលារៀនដោយខ្លួនឯង គឺមិនត្រឹមតែកំណត់ថា តើមានកត្តាលើកលែងជាក់លាក់ណាមួយដែលត្រូវបានបង្ហាញនោះទេ ប៉ុន្តែថែមទាំង ដើម្បីស្វែងរកកត្តាដែលបង្កធ្វើឱ្យកុមារប្រឈមនឹងការផាត់ចេញពីសង្គមក្នុងប្រព័ន្ធអប់រំ។ ដំណើរការនៃការសង្កេតទាំងនេះ ត្រូវបានគេហៅថា ការវិភាគការផាត់ចេញពីសង្គម និងយេនឌ័រ (SEGA)។ ការសង្កេតត្រូវធ្វើឡើង តាមរយៈការសិក្សាស្រាវជ្រាវប្រតិបត្តិបែបសាមញ្ញមួយ ដើម្បីឱ្យយល់កាន់តែច្បាស់នូវកត្តាដែលបង្កឱ្យមានការផាត់ចេញពីសង្គម និងធ្វើបទអន្តរាគមន៍ឱ្យទាន់ពេលវេលា នៅពេលដែលព័ត៌មានប្រមូលបាន ហើយធ្វើការវិភាគរកភស្តុតាង ដើម្បីដាក់បញ្ចូលទៅក្នុង ESP ឬ AOP។ វាពិតជាមានសារៈសំខាន់ណាស់ដែលការធ្វើផែនការប្រកបដោយគុណភាព និងមានភស្តុតាងច្បាស់លាស់ ដើម្បីដោះស្រាយ និងលុបបំបាត់ការផាត់ចេញពីសង្គម។

## ៣.៣- ការផាត់ចេញពីសង្គមទៅជាការអប់រំបរិយាបន្ននៅថ្នាក់ភូមិ និងសាលារៀន បទពិសោធពីខេត្តរតនគិរី

ខេត្តរតនគិរីត្រូវបានជ្រើសរើស ដើម្បីសិក្សាពីទិដ្ឋភាពមួយនៃការផាត់ចេញពីសង្គមដោយផ្ទាល់ ពីព្រោះខេត្តនេះ សម្បូរទៅដោយសិស្សមកពីក្រុមជនជាតិដើមភាគតិចដែលរស់នៅទីនោះ(មានដូចជា: ជនជាតិ ចារាយ ទំពួន គ្រឹង។ល។)។ ការសិក្សាស្រាវជ្រាវខ្លីមួយត្រូវបានអនុវត្តដោយការធ្វើការសម្ភាសបុគ្គល និងក្រុមនៅសាលារៀនចំនួន ៥៖

- វិទ្យាល័យអន្តេវាសិកដ្ឋានក្រុងបានលុង
- វិទ្យាល័យលំផាត់
- អនុវិទ្យាល័យប៉ាកយ៉ាយ
- សាលាបឋមសិក្សាយក្សឡោម
- សាលាបឋមសិក្សាក្រឡា

សិស្សមួយចំនួនមកពីសាលាទាំងនេះបានបង្ហាញថា កត្តាសេដ្ឋកិច្ច វប្បធម៌ សង្គម នយោបាយ និងកត្តាបុគ្គល ដែលនាំឱ្យសិស្សជួបប្រទះបញ្ហាការផាត់ចេញពីការអប់រំ។ ទិន្នន័យដែលប្រមូលបាន ពីសាលាទាំង ៥ បានបង្ហាញពីមូលហេតុនៃបញ្ហាផាត់ចេញនៅកម្រិតសាលារៀនទាំងនោះគឺ៖

### ៣.៣.១- ភាសាដែលត្រូវបានប្រើក្នុងថ្នាក់រៀន (ភាសាឡាវ ទំពួន និងចារាយ)

ការអនុវត្តកម្មវិធីអប់រំពហុភាសារបស់រាជរដ្ឋាភិបាល បានធ្វើឱ្យភាសាកំណើតត្រូវបានប្រើប្រាស់នៅតាមសាលារៀន នៅកម្រិតមត្តេយ្យសិក្សាបាន១០០% ហើយ នៅថ្នាក់ទី១ បាន៨០% នៅថ្នាក់ទី២ បាន៦០% និងនៅថ្នាក់ទី៣ បាន ៣០%។ ចាប់ពីថ្នាក់ទី៤ រាល់ការបង្រៀនទាំងអស់ត្រូវប្រើតែភាសាខ្មែរ។

សិស្សបានអះអាងថា ពួកគេប្រើភាសាកំណើតរបស់ពួកគេនៅផ្ទះជាមួយឪពុកម្តាយ ក្រុមគ្រួសារ និងមិត្តភក្តិ។ ហេតុដូច្នេះហើយ សិស្សជនជាតិដើមភាគតិចខ្លះយល់ថា ភាសាខ្មែរពិបាករៀន ដូចនេះពេលខ្លះគ្រូត្រូវការប្រើភាសាកំណើតដើម្បីពន្យល់អត្ថន័យនៃពាក្យ។

បទអន្តរាគមន៍ដែលនាំឱ្យមានការអប់រំបរិយាបន្ន៖

- ☞ ពង្រឹងគុណភាពនៃការបង្រៀន និងការរៀន ជាពិសេសគ្រូពហុភាសា ដើម្បីធានាថាសិស្សអាចរៀន និងប្រើប្រាស់ភាសាខ្មែរចាប់ពីថ្នាក់ទី៤ ឡើងទៅ
- ☞ ពង្រីកការអប់រំពហុភាសានៅកន្លែងដែលចាំបាច់។

### ៣.៣.២- ហេដ្ឋារចនាសម្ព័ន្ធសាលារៀន

ដោយសារកង្វះខាតបន្ទប់រៀននៅតាមតំបន់មួយចំនួន និងចំនួនសិស្សនៅក្នុងថ្នាក់រៀនមានច្រើនដូច្នេះ សិស្សខ្លះមានការលំបាកក្នុងការសិក្សា។ លើសពីនេះទៅទៀត មានការខ្វះខាតបង្គន់អនាម័យ និងហេដ្ឋារចនាសម្ព័ន្ធសាលារៀននៅតាមសាលាមួយចំនួន។ បញ្ហាមួយទៀត គឺកង្វះកន្លែងស្នាក់នៅ ដោយសិស្សជនជាតិដើមភាគតិចជាច្រើនរស់នៅឆ្ងាយពីសាលារៀន ហើយខ្វះមធ្យោបាយធ្វើដំណើរ។ ម្យ៉ាងទៀត សិស្សក៏ផ្លាស់ប្តូរពីតំបន់មួយទៅតំបន់មួយទៀត ដោយសារការផ្លាស់ប្តូរដំណាំតាមរដូវ។ ក្នុងស្ថានភាពទាំងនេះ អន្តេវាសិកដ្ឋានមានសារៈសំខាន់ណាស់ក្នុងការធានាការអប់រំ សម្រាប់សិស្សអនុវិទ្យាល័យឱ្យបន្តការសិក្សា និងដើម្បីកាត់បន្ថយបញ្ហានៃការបោះបង់ការសិក្សា។

បទអន្តរាគមន៍ដែលនាំឱ្យមានការអប់រំបរិយាបន្ន៖

- ☞ រាជរដ្ឋាភិបាលត្រូវផ្តល់លទ្ធភាពឱ្យសិស្សអាចសិក្សា នៅសាលារៀនក្បែរផ្ទះរបស់ពួកគេ ដោយការសាងសង់សាលារៀនបន្ថែមទៀត ដែលអាចជួយដល់សិស្សកុំឱ្យផ្លាស់ទីលំនៅពីតំបន់មួយទៅតំបន់មួយទៀតតាមរដូវដាំដុះ

- ☞ បង្កើនចំនួនអន្តេវាសិកដ្ឋាន ដើម្បីធ្វើឱ្យសិស្សកាន់តែច្រើនបានចូលរៀននៅសាលាល្អៗ និងជៀសវាងការរំខានដល់កាសិក្សារបស់ពួកគេ
- ☞ ផ្តល់មធ្យោបាយធ្វើដំណើរ ដូចជា កង់ ឬជួលឡានសម្រាប់សិស្ស តាមរយៈការរៃអង្គាសថវិកាពីសប្បុរសជន និងសហគមន៍។

## ៣.៣.៣- សាសនា និងវប្បធម៌ផ្សេងៗគ្នាត្រូវបានផាត់ចេញពីសង្គម

ឪពុកម្តាយរបស់សិស្សជនជាតិដើមភាគតិចចូលចិត្តរស់នៅក្នុងក្រុមជនជាតិដើមរបស់ពួកគេ។ ដូច្នេះ សិស្សមានទម្លាប់រស់នៅជាច់ដោយឡែកក្នុងវប្បធម៌របស់ពួកគេ ហើយញែកខ្លួនចេញពីការរស់នៅក្នុងពហុវប្បធម៌។

ការអន្តរាគមន៍ដែលនាំឱ្យមានការអប់រំបរិយាបន្ន៖

- ☞ ផ្សព្វផ្សាយសិទ្ធិ សាសនា និងបង្កើតការជួបជុំសម្រាប់មេដឹកនាំសាសនា
- ☞ អប់រំជនជាតិដើមឱ្យយល់ដឹងកាន់តែច្បាស់អំពីការរស់នៅក្នុងសង្គមពហុវប្បធម៌តាមរយៈការអប់រំពលរដ្ឋ។

## ៣.៣.៤- ការផ្តល់សេវាអប់រំនៅក្នុងសាលារៀននិងការរៀនមិនគ្រប់គ្រាន់

កង្វះគុណភាពនៃការបង្រៀន ការពង្រាយគ្រូដែលមិនឆ្លើយតបទៅនឹងតម្រូវការ និងការធ្វេសប្រហែសនៃការបង្រៀននៅសាលារៀនសាធារណៈ បានបង្កការលំបាកដល់សិស្សក្នុងការទទួលបាននូវចំណេះដឹង និងជំនាញចាំបាច់។ កត្តាទាំងនេះធ្វើឱ្យសិស្សបោះបង់ការសិក្សា ហើយចំណាយពេលតិចនៅសាលារៀន ជាពិសេស សិស្សនៅអនុវិទ្យាល័យនិងវិទ្យាល័យ។

បទអន្តរាគមន៍ដែលនាំឱ្យមានការអប់រំបរិយាបន្ន៖

- ☞ លើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាលគ្រូ
- ☞ ផ្តល់សេវាអប់រំគ្រប់គ្រាន់ (បង្កើនការបង្រៀនឥតគិតថ្លៃដល់អ្នករៀនយឺត)

## ៣.៣.៥- កង្វះសេរីភាពនិងសមភាពក្នុងបរិបទថ្នាក់រៀន

ដោយសារសិស្សចាប់ពីថ្នាក់ទី៤ ឡើងទៅ តម្រូវឱ្យរៀនភាសាខ្មែរ សិស្សជនជាតិដើមភាគតិចខ្លះមិនសូវចូលរួមក្នុងសកម្មភាពថ្នាក់រៀនទេ ព្រោះខ្លាចសិស្សដទៃទៀតសើចចំអក នៅពេលដែលពួក

គេអានមិនត្រឹមត្រូវ ឬនិយាយមិនច្បាស់។ ហេតុនេះធ្វើឱ្យមានការកាត់បន្ថយការទំនាក់ទំនងជាមួយមិត្តរួមថ្នាក់និងគ្រូ។

បទអន្តរាគមន៍ដែលនាំឱ្យមានការអប់រំបរិយាបន្ន៖

☞ បង្កើនការយល់ចិត្ត ដោយផ្តល់សិទ្ធិស្មើគ្នាដល់សិស្សទាំងអស់នៅក្នុងថ្នាក់ និងបណ្តុះបណ្តាលគ្រូឱ្យធ្វើជាគំរូក្នុងការទទួលយកភាពខុសគ្នា

☞ លើកទឹកចិត្តសិស្សជនជាតិដើមភាគតិចឱ្យបញ្ចេញមតិរបស់ពួកគេកុំមានអារម្មណ៍អៀនខ្មាស។

## ៣.៣.៦- បច្ចេកវិទ្យា

នៅក្នុងយុគសម័យឌីជីថល ការប្រើប្រាស់អ៊ិនធឺណែត និងស្មាតហ្វូនបានក្លាយជាការពេញនិយមក្នុងចំណោមសិស្សមិនថា នៅទីប្រជុំជន ឬជនបទទេ។ ឥទ្ធិពលនៃបច្ចេកវិទ្យាបានពង្រីកគម្លាតរវាងសិស្សដែលមិនអាចមានលទ្ធភាពទិញ និងប្រើប្រាស់ស្មាតហ្វូនបាន។

បទអន្តរាគមន៍ដែលនាំឱ្យមានការអប់រំបរិយាបន្ន៖

☞ គ្រូបង្រៀនត្រូវអប់រំសិស្សអំពីឥទ្ធិពលនៃសម្ភារៈនិយម

☞ គ្រូបង្រៀនត្រូវតែទទួលបានការបណ្តុះបណ្តាល ដើម្បីឱ្យមានចំណេះដឹងទាក់ទងទៅនឹងបច្ចេកវិទ្យា ដូច្នេះ ពួកគាត់អាចគាំទ្រដល់សិស្សរបស់ខ្លួនក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានដើម្បីជាអត្ថប្រយោជន៍ក្នុងការរៀនសូត្រ

☞ ហាមឃាត់ការប្រើប្រាស់គេហទំព័រ ដែលជះឥទ្ធិពលអវិជ្ជមានដល់ការរៀនសូត្ររបស់សិស្ស

☞ អប់រំឪពុកម្តាយឱ្យណែនាំកូនៗ អំពីវិបត្តិនៃសម្ភារៈនិយម និងដឹងពីរបៀបឆ្លើយតបទៅនឹងតម្រូវការសម្ភារៈនិយមរបស់កូនៗពួកគេ។

## ៣.៣.៧- កង្វះខាតស្តង់ដាគ្រូ និងគំរូមិនល្អគ្រប់គ្រាន់

វឌ្ឍនភាពនៃការរៀនសូត្ររបស់សិស្សពីកម្រិតមួយទៅកម្រិតមួយ ពឹងផ្អែកទៅលើការបង្រៀនដែលមានអាកប្បកិរិយាប្រកបដោយក្រមសីលធម៌។ គ្រូដែលប្រើកាយវិការមិនសមរម្យ ពាក្យស្តីបន្ទោស និងខ្វះការលើកទឹកចិត្តគឺជាគំរូមិនល្អសម្រាប់សិស្ស និងនាំឱ្យសិស្សឈប់ទៅសាលារៀន ដែលបណ្តាលឱ្យពួកគេមានការបោះបង់ការសិក្សាកាន់តែកើនឡើង។

បទអន្តរាគមន៍ដែលនាំឱ្យមានការអប់រំបរិយាបន្ន៖

☞ នាយកសាលាត្រូវអនុវត្តតាមបទដ្ឋានច្បាប់របស់ក្រសួង (អនុក្រឹត្យលេខ ៥៦ ក្រមសីលធម៌គ្រូបង្រៀន និងលក្ខន្តិកៈទូទៅនៃមន្ត្រីរាជការស៊ីវិល) ផ្តល់ឱកាសក្នុងការបង្រៀនគ្រូឱ្យគោរពក្រមសីលធម៌វិជ្ជាជីវៈ។

### ៣.៣.៨- និន្នាការនយោបាយរវាងគ្រូបង្រៀន សិស្ស និងស្ថាប័នគ្រប់គ្រង

សម្ព័ន្ធភាពនយោបាយរបស់គណបក្ស ជំរុញការបង្កើតក្រុម និងបក្សពួកផងដែរ។ នៅកម្រិតសាលារៀន ការជជែកដេញដោលផ្នែកនយោបាយមិនត្រូវបានអនុញ្ញាតទេ។ គ្មានការឃោសនា ឬការប្រើប្រាស់សាលារៀនជាកន្លែងផ្សព្វផ្សាយនយោបាយឡើយ។

បទអន្តរាគមន៍ដែលនាំឱ្យមានការអប់រំបរិយាបន្ន៖

☞ ហាមឃាត់មិនឱ្យមាននិន្នាការនយោបាយនៅតាមសាលារៀន
☞ អប់រំគ្រូនិងសិស្សកុំឱ្យដើរតាមនិន្នាការនយោបាយក្នុងសាលារៀន។

## ៣.៤- ប្រព័ន្ធអប់រំដាច់ដោយឡែក និងប្រព័ន្ធអប់រំបរិយាបន្ននៅកម្រិតការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលខណ្ឌ-ក្រុង-ស្រុក (DOE )

ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលខណ្ឌ-ក្រុង-ស្រុក ដើរតួជាអ្នកសម្របសម្រួលក្នុងការដោះស្រាយបញ្ហាប្រឈមនានានៅតាមសាលារៀន និងរាយការណ៍បន្តទៅមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត។ កត្តាដែលត្រូវប្រើប្រាស់ប្រព័ន្ធអប់រំដាច់ដោយឡែកនៅកម្រិតអប់រំថ្នាក់ខណ្ឌ ក្រុង ស្រុករួមមាន៖

### ៣.៤.១- កង្វះការយល់ដឹងនៅក្នុងសហគមន៍ទាក់ទងនឹងតម្រូវការនៃការអប់រំល្អ

នៅកម្រិតការអប់រំមូលដ្ឋាន ការពង្រឹងគុណភាពអប់រំគឺអាស្រ័យលើការគាំទ្រនិងសហប្រតិបត្តិការរបស់សហគមន៍នោះផ្ទាល់។ ការមិនផ្តល់តម្លៃដល់ការអប់រំ បានធ្វើឱ្យបាត់ឱកាសសិក្សារបស់សិស្ស ធ្វើឱ្យពួកគេអសមត្ថភាពក្នុងការបន្តការសិក្សា ហើយជាលទ្ធផលពួកគេត្រូវបោះបង់ចោលការសិក្សាទាំងនៅក្មេង។

បទអន្តរាគមន៍ដែលនាំឱ្យមានការអប់រំបរិយាបន្ន៖

- ☞ ផ្សព្វផ្សាយដល់សហគមន៍នូវគុណតម្លៃនៃការអប់រំ និងបទពិសោធនៃការរៀនសូត្រដែលទទួលបានជោគជ័យ
- ☞ យុទ្ធនាការ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីតម្រូវការសម្រាប់ការអប់រំល្អ (ការធ្វើសារបិទបដា) និងអត្ថប្រយោជន៍រយៈពេលវែងនៃការអប់រំ។

## ៣.៤.២- ឪពុកម្តាយរបស់សិស្សដែលមិនបានទទួលការអប់រំ និងមានមុខរបរមិនច្បាស់លាស់

សិស្សខ្លះមានឪពុកម្តាយដែលប្រើប្រាស់គ្រឿងស្រវឹង និងលេងល្បែងស៊ីសងជាប្រចាំ។ ក្នុងករណីទាំងនេះ ឪពុកម្តាយមិនអាចផ្តល់កម្លាំងចិត្ត គាំទ្រ និងលើកទឹកចិត្តដល់កូនៗរបស់ពួកគេបានទេ។ កត្តាកង្វះការអប់រំ កត្តាបរិយាកាសរស់នៅ និងបញ្ហាក្នុងគ្រួសារ បានធ្វើឱ្យសិស្សមួយចំនួនបំពេញកិច្ចការមិនបានល្អក្នុងការសិក្សារបស់ពួកគេ ក៏ដូចជាមានអវត្តមានច្រើន។ សិស្សទាំងនេះនឹងចាប់ផ្តាច់ខ្លួនគេចេញពីមិត្តភក្តិ និងសង្គមរបស់គេ។

បទអន្តរាគមន៍ដែលនាំឱ្យមានការអប់រំបរិយាបន្ន៖

- ☞ សហការជាមួយអាជ្ញាធរពាក់ព័ន្ធ ដើម្បីផ្តល់ការប្រឹក្សាជាអាជីព កម្មវិធីសិក្សាអក្សរសិល្ប៍ និងការណែនាំអំពីផលប៉ះពាល់នៃការញៀន គ្រឿងស្រវឹង និងល្បែងស៊ីសង។

## ៣.៥- ការផាត់ចេញពីប្រព័ន្ធអប់រំ ទៅជាប្រព័ន្ធអប់រំបរិយាបន្ននៅកម្រិតមន្ទីរ អយក ខេត្ត (POE)

មន្ទីរ អយក ខេត្ត ធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងអប់រំ យុវជន និងកីឡា។ មានកត្តាជាច្រើនដែលបង្កឱ្យមានបញ្ហាការផាត់ចេញពីសង្គមក្នុងវិស័យអប់រំ នៅកម្រិតមន្ទីរ អយក ខេត្ត ដែលវាជាបញ្ហាត្រូវការការយកចិត្តទុកដាក់ខ្ពស់ពីកអ្នករៀបចំផែនការអប់រំខេត្ត។

## ៣.៥.១- សាលារៀនខ្លះមិនមាននាយកសាលានិងជួលតែគ្រូបង្រៀនក្នុងស្រុកមួយចំនួនតូច

ការអប់រំប្រកបដោយសមធម៌ និងបរិយាបន្ន អាស្រ័យលើអ្នកដឹកនាំសាលាពូកែ និងមានគ្រូបង្រៀនគ្រប់គ្រាន់ ស្របតាមតម្រូវការរបស់សាលារៀន។ ការគ្រប់គ្រងការបង្រៀន និងការរៀនរបស់គ្រូនិងសិស្សមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីធានានូវគុណភាពនៃការរៀនរបស់សិស្ស។

បទអន្តរាគមន៍ដែលនាំឱ្យមានការអប់រំបរិយាបន្ន៖

☞ ពន្លឿនការតែងតាំងនាយកសាលា ដែលទទួលបានការបណ្តុះបណ្តាលរួច
☞ បង្កើនប្រាក់ឧបត្ថម្ភសម្រាប់គ្រូថ្មី ដែលបង្រៀននៅតំបន់ដាច់ស្រយាល និងតំបន់ខ្ពង់រាប។

## ៣.៥.២- ការអភិវឌ្ឍក្នុងស្រុកយឺត

នៅតំបន់មានការអភិវឌ្ឍយឺត មានមនុស្សតិចតួចណាស់ ដែលមានចំណេះដឹង និងជំនាញ ដើម្បីទទួលបានការងារធម្មតាមួយបាន។ កត្តាជីវភាពបានជំរុញឱ្យឪពុកម្តាយសិស្ស ផ្លាស់ប្តូរទីលំនៅ និងខកខានមិនបានបញ្ជូនកូនៗឱ្យទៅរៀនថែមទៀតផង។

បទអន្តរាគមន៍ដែលនាំឱ្យមានការអប់រំបរិយាបន្ន៖

☞ បង្កើនការផ្តល់អាហារូបករណ៍សម្រាប់សិស្សក្រីក្រ និងបណ្តុះបណ្តាលសម្រាប់ឱកាសការងារនាពេលអនាគត និងបង្កើនចំនួនមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ (TVET)
☞ ស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ចូលរួមបង្កើតការងារអចិន្ត្រៃយ៍នៅក្នុងស្រុក ដោយបង្កើតទីផ្សារការងារ និងបង្កើនការវិនិយោគក្នុងស្រុក
☞ ជំរុញការអភិវឌ្ឍក្នុងស្រុកប្រកបដោយតម្លាភាព និងកសាងហេដ្ឋារចនាសម្ព័ន្ធបន្ថែម។

## ៣.៥.៣- ការធ្វើផែនការផ្អែកលើភស្តុតាង និងគុណភាព

មន្ទីរអប់រំ យុវជន និងកីឡា មាននាទីទទួលខុសត្រូវចំពោះការរៀបចំផែនការយុទ្ធសាស្ត្រអប់រំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ សម្រាប់ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលខណ្ឌ-ក្រុង-ស្រុក និងសាលារៀន។ ដូច្នេះ មន្ទីរអប់រំ យុវជន និងកីឡា គួរជានាឱ្យបានលើការប្រមូលភស្តុតាង របស់សិស្សដែលងាយរងគ្រោះក្នុងរាជធានី ខេត្ត របស់ពួកគេ តាមរយៈវិភាគការផាត់ចេញពីសង្គម និងយេនឌ័រ (SEGA) ដែលត្រូវលើកឡើងជាផែនការសកម្មភាព ដ៏សមស្របជាមួយនឹងការកំណត់ទំហំកញ្ចប់ថវិកានឹងទំហំការងារ ឱ្យមានភាពប្រាកដនិយម។ មន្ទីរអប់រំ យុវជន និងកីឡា ត្រូវជានាដល់ការពិនិត្យតាមដានដំណើរការរៀបចំផែនការនេះ ដើម្បីធ្វើឱ្យបាននូវធ្វើផែនការប្រកបដោយគុណភាព និងមានភាពច្បាស់លាស់នៅគ្រប់កម្រិត។ ដូច្នេះ បញ្ហាការផាត់ចេញពីសង្គមនឹងត្រូវបានដោះស្រាយជាប្រចាំ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។ មន្ទីរអប់រំ យុវជន និងកីឡា ត្រូវតែមានភាពច្បាស់លាស់ក្នុងការបំពេញការងារឱ្យជាប់ជាប្រចាំ ដើម្បីឆ្ពោះទៅរកការអនុវត្តការអប់រំបរិយាបន្ននៅក្នុងសាលារៀនរបស់ពួកគេ។

## ៣.៦- កម្រិតក្រសួងអប់រំ យុវជន និងកីឡា

### ៣.៦.១- ការអប់រំបរិយាបន្ន

នៅឆ្នាំ ២០១៧ ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតវិទ្យាស្ថានជាតិសម្រាប់ការអប់រំពិសេស ដើម្បីគាំទ្រដល់ការបណ្តុះបណ្តាលជំនាញសម្រាប់គ្រូទាំងឡាយណា ដែលមានបំណងចង់បង្កើនចំណេះដឹង និងការយល់ដឹងរបស់ពួកគេក្នុងការធ្វើការជាមួយកុមារមានពិការភាព ឬកុមារដែលមានតម្រូវការសិក្សាពិសេស។ ក្នុងឆ្នាំ ២០១៦ មូលនិធិគ្រួសារថ្មី (KTF) បានផ្ទេរសាលាចំនួន ៥ សម្រាប់កុមារដែលពិការភ្នែក និងត្រចៀក ឱ្យមកស្ថិតនៅក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលវិញ។ សាលារៀនទាំងនេះ ត្រូវបានប្តូរទៅជាវិទ្យាល័យអប់រំពិសេសនៅក្នុងឆ្នាំសិក្សា២០១៧-២០១៨ (KTF ២០១៧)។

ការបង្កើតវិទ្យាស្ថានជាតិសម្រាប់ការអប់រំពិសេស (NISE) និងសាលាអប់រំពិសេស ជួយឱ្យកុមារដែលមានតម្រូវការអប់រំពិសេស ទទួលបានការអប់រំសមស្របមួយ ប្រកបដោយគុណភាពខ្ពស់ និងផ្តល់ឱ្យពួកគេនូវឱកាស ដើម្បីចូលរួមទៅក្នុងសង្គម។ គំនិតផ្តួចផ្តើមនេះបានលើកទឹកចិត្តយ៉ាងខ្លាំងដល់កុមារ ដែលត្រូវបានផាត់ចេញពីសង្គមឱ្យត្រលប់ទៅសាលារៀនវិញ និងបញ្ចប់ការសិក្សារបស់ពួកគេ។ វាក៏ជំរុញឱ្យឪពុកម្តាយបញ្ឈប់ការលាក់បាំងពិការភាពកូនៗរបស់ពួកគេ និងអនុញ្ញាតឱ្យកូនបានចូលក្នុងប្រព័ន្ធអប់រំ។

### ៣.៦.២- ការអប់រំពហុភាសា

ក្រសួងអប់រំ យុវជន និងកីឡាបានខិតខំប្រឹងប្រែង ដើម្បីផ្តល់លទ្ធភាពឱ្យទទួលបានការអប់រំដែលមានគុណភាពដល់កុមារមកពីសហគមន៍ជនជាតិដើមភាគតិច តាមរយៈផែនការសកម្មភាពអប់រំពហុភាសា (MEAP) ២០១៩-២០២៣ (MoEYS, ២០១៩)។ តាមរយៈការអនុវត្តរបស់កុមារមកពីក្រុមជនជាតិដើមភាគតិចផ្សេងៗ ទទួលបានការអប់រំបរិយាបន្នរបស់រដ្ឋ ដែលត្រូវជានាឱ្យមានការផ្សារភ្ជាប់ទៅនឹងភាសាកំណើត វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់របស់ជនជាតិដើមភាគតិចទាំងនោះ (MoEYS, 2019)។

### ៣.៦.៣- សមភាពយេនឌ័រ

ប្រទេសកម្ពុជា បានចុះហត្ថលេខាលើអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពី ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ [១៦] (CEDAW) និងបានបង្ហាញពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការលុបបំបាត់ការរើសអើងទៅលើក្មេងស្រី និងស្ត្រីនៅក្នុងវិស័យអប់រំ។ CEDAW ទទួលស្គាល់ថា ការចូលរួមពេញលេញរបស់ស្ត្រីគឺជាភាពចាំបាច់សម្រាប់ការអភិវឌ្ឍប្រទេស។ ក្នុងនាមជាប្រទេសហត្ថលេខីនៃ CEDAW ប្រទេសកម្ពុជាបានព្យាយាមលើកកម្ពស់ការផ្តល់សិទ្ធិអំណាចដល់ស្ត្រីក្នុងវិស័យ

អប់រំ ចាប់តាំងពីឆ្នាំ២០០៧ មក តាមរយៈការបញ្ជ្រាបយេនឌ័រ នៅក្នុងគោលនយោបាយអប់រំ និងផែនការសកម្មភាព។

នៅឆ្នាំ ២០១៥ ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ (ឆ្នាំ ២០១៦-២០២០)។ ក្នុងឆ្នាំ ១៩៩៧ ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ (ECOSOC) បានកំណត់និយមន័យនៃការបញ្ជ្រាបយេនឌ័រថា៖

> *"ការបញ្ជ្រាបទស្សនវិស័យយេនឌ័រ ... គឺជាយុទ្ធសាស្ត្រមួយសម្រាប់ធ្វើឱ្យមានការយកចិត្តទុកដាក់ និងបទពិសោធរបស់ស្ត្រីក៏ដូចជាបុរស ដែលជាផ្នែកសំខាន់មួយនៃរចនាបទ ការអនុវត្ត ការពិនិត្យតាមដាន និងវាយតម្លៃគោលនយោបាយ និងកម្មវិធីនៅគ្រប់វិស័យនយោបាយ សេដ្ឋកិច្ច និងសង្គម។ ដូច្នេះ ស្ត្រីនិងបុរសទទួលបានផលប្រយោជន៍ស្មើៗគ្នា ហើយវិសមភាពនឹងអាចលុបបំបាត់បាន។ គោលដៅចុងក្រោយនៃការបញ្ជ្រាបគឺដើម្បីទទួលបានសមភាពយេនឌ័រ"។*

ផែនការយុទ្ធសាស្ត្រវិស័យការអប់រំ(២០១៩-២០២៣) និងគោលនយោបាយស្តីពីចក្ខុវិស័យឧត្តមសិក្សាឆ្នាំ២០៣០ របស់ក្រសួងអប់រំ យុវជន និងកីឡា បន្តដោះស្រាយបញ្ហាយេនឌ័រក្នុងការអប់រំគ្រប់កម្រិត តាមរយៈការប្រើប្រាស់កម្មវិធីអាហារូបករណ៍ថ្នាក់ជាតិ និងការអភិវឌ្ឍសមត្ថភាពសម្រាប់ស្ត្រី។

ការអប់រំគឺជាមធ្យោបាយដ៏មានឥទ្ធិពលបំផុត ក្នុងការសម្រេចបាននូវសមភាពយេនឌ័រ ដែលធ្វើឱ្យក្មេងស្រី និងស្ត្រីអាចចូលរួមពេញលេញនៅក្នុងសង្គម និងនយោបាយ ហើយផ្តល់សិទ្ធិអំណាចដល់ពួកគេលើផ្នែកសេដ្ឋកិច្ចផងដែរ (ការអប់រំ ២០៣០)។

## ៣.៦.៤- ទំនោរផ្លូវភេទ (រួមទាំងមេរោគអេដស៍)

នៅឆ្នាំ២០១៦-១៧ ក្រសួងអប់រំ យុវជន និងកីឡា ដោយមានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលបានបើកកម្មវិធីសិក្សាបំណិនជីវិតសម្រាប់ថ្នាក់ទី៥-១១ និងសម្រាប់យុវជនក្រៅសាលារៀន។ កម្មវិធីសិក្សាថ្មីរួមមាន៖ ការអប់រំបន្តពូជកម្រិតមូលដ្ឋាន និងការអប់រំសុខភាពរួមមាន ជំងឺអេដស៍ អនាម័យ និងទស្សនៈយេនឌ័រ តួនាទីយេនឌ័រ ភេទ និងការបញ្ចេញមតិពីយេនឌ័រ ក៏ដូចជាសិទ្ធិមនុស្ស សមភាពយេនឌ័រ ការយាយីផ្លូវភេទ និងអំពើហិង្សាផ្លូវភេទ។ ដូច្នេះ កម្មវិធីសិក្សាថ្មីផ្តល់នូវការណែនាំជាក់លាក់ និងបញ្ចូលគ្នាលើបញ្ហាអ្នកស្រឡាញ់ភេទដូចគ្នា។ បញ្ហាប្រឈមចម្បងក្នុងការទទួលបានជោគជ័យនៃកម្មវិធីសិក្សាពីយេនឌ័រដ៏ទូលំទូលាយ គឺការបង្កើតសៀវភៅសិក្សាដ៏សាកសមមួយ និងការកសាងសមត្ថភាពរបស់គ្រូ ដើម្បីឱ្យពួកគាត់អាចបង្រៀនតាមខ្លឹមសារយ៉ាងមានប្រសិទ្ធភាព។

# ជំពូក ៤ សេចក្តីសន្និដ្ឋាន និងមាគ៌ាឆ្ពោះទៅមុខ

សៀវភៅនេះ មានការប្រមូលផ្តុំនូវគំនិតសំខាន់ៗស្តីពី បញ្ហាជាក់ស្តែងនៃការផាត់ចេញពីសង្គមនៅក្នុងបរិបទកម្ពុជា។ អ្នករៀបរៀងសង្ឃឹមថា ព័ត៌មានដែលមាននៅក្នុងសៀវភៅនេះ នឹងត្រូវបានប្រើប្រាស់ ដើម្បីកែលម្អការយល់ដឹងរបស់អ្នកដែលធ្វើការក្នុងវិស័យអប់រំ និងលើកកម្ពស់ការយល់ដឹងអំពីបញ្ហានៃការផាត់ចេញពីសង្គម ការលំបាក និងការរើសអើងចំពោះកុមារ ដែលធ្វើឱ្យពួកគេមិនបានចុះឈ្មោះចូលរៀន ឬកុមារដែលប្រឈមនឹងការបោះបង់ការសិក្សាមុនការបញ្ចប់ការអប់រំមូលដ្ឋានរបស់ខ្លួន។ កត្តាដែលធ្វើឱ្យមានការផាត់ចេញពីសង្គម ដែលកើតឡើងជារឿយៗ នៅក្នុងតំបន់មួយចំនួនក្នុងប្រទេសកម្ពុជា ដែលបានទទួលស្គាល់ដោយមន្ទីរ អប់រំ យុវជន និងកីឡា រាជធានី ខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសាលារៀន ដែលអាចបន្តដោះស្រាយជាមួយបញ្ហាដូចជា អត្រាបោះបង់ការសិក្សាខ្ពស់ ការចូលរៀនមិនទៀងទាត់ និងអត្រាបញ្ចប់ការសិក្សាទាបជាដើម។

បញ្ហាទាំងអស់នេះនឹងត្រូវបានដោះស្រាយជាចាំបាច់ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព SDG-4 ក៏ដូចជាគោលដៅអប់រំឆ្នាំ២០៣០ ដែលក្រសួងអប់រំ យុវជន និងកីឡាបានកំណត់ថា អ្នករៀបចំផែនការគ្រប់កម្រិតត្រូវធ្វើការវិភាគលើការផាត់ចេញពីសង្គម និងយេនឌ័រ នៅក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងសាលារៀនរបស់ពួកគេមុននឹងធ្វើផែនការ។ ដូច្នេះ បញ្ហាដែលពាក់ព័ន្ធនឹងការផាត់ចេញពីសង្គមត្រូវបានបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ (ESP) និងផែនការប្រតិបត្តិការប្រចាំឆ្នាំ (AOP)។

ក្នុងការធ្វើឱ្យប្រសើរឡើងនូវការយល់ដឹងអំពីការផាត់ចេញពីសង្គម ភាគីពាក់ព័ន្ធទាំងអស់នឹងត្រូវយល់ដឹងឱ្យបានច្បាស់នូវចក្ខុវិស័យសម្រាប់ការអប់រំប្រកបដោយបរិយាបន្ន និងសមធម៌ដូចមានចែងនៅក្នុង SDG-4 ដែលសេចក្តីប្រកាសអ៊ិនឈុន (១)ថ្លែងថា៖

> *"... ការអប់រំគឺជាគុណប្រយោជន៍សាធារណៈ សិទ្ធិជាមូលដ្ឋានរបស់មនុស្ស និងជាមូលដ្ឋានគ្រឹះសម្រាប់ធានាដល់ការសម្រេចបាននូវសិទ្ធិផ្សេងៗទៀត។ វាចាំបាច់សម្រាប់សន្តិភាព ការអត់ធ្មត់ ការបំពេញកិច្ចការរបស់មនុស្ស និងការអភិវឌ្ឍប្រកបដោយចីរភាព។ យើងទទួលស្គាល់ថា ការអប់រំជាគន្លឹះដើម្បីសម្រេចបានការងារពេញលេញ និងលុបបំបាត់ភាពក្រីក្រ។ យើងនឹងយកចិត្តទុកដាក់ខិតខំប្រឹងប្រែងឱ្យអស់ពីលទ្ធភាព ដើម្បីទទួលបាននូវលទ្ធផលប្រកបដោយគុណភាព សមធម៌ បរិយាបន្ន និងសិក្សាពេញមួយជីវិត"។*

# ឯកសារយោង

[1] UNESCO (2015) Education 2030. *World Education Forum 2015*, 51-51. Retrieved from https://en.unesco.org/world-education-forum-2015/incheon-declaration

[2] Cambodia's Education 2030 Roadmap (2019) https://www.moeys.gov.kh/index.php/en/planning/2901.html#.YFlkI68zbIU

[3] United Nation Convention on the Rights of the Child: https://www.unicef.org/child-rights-convention

[4] Kalyanpur M. (2011) Paradigm and Paradox: Education for All and the inclusion of children with disabilities in Cambodia, *International Journal of Inclusive Education*, 15 (10) 1–19

[5] DFID policy paper (2005), Reducing poverty by tackling social exclusion, Department for International Development, UK

[6] UNICEF (2003) Inclusive Education Initiatives for Children with Disabilities: Lessons from the East Asia and Pacific Region

[7] Promoting Social Inclusion in Cambodia, Disability Action Council (Cambodia) January 2017

[8] Perignon M, et al (2014) Stunting, Poor Iron Status and Parasite Infection Are Significant Risk Factors for Lower Cognitive Performance in Cambodian School-Aged Children, PLOS ONE, Open Access Journal *https://doi.org/10.1371/journal.pone.0112605*

[9] Anderson E. & Kelly G. (2018) From Schoolgirls to "Virtuous" Khmer Women: Interrogating *Chbab Srey* and Gender in Cambodian Education Policy, Studies in Social Justice, *Volume 12, Issue 2, pp - 215-234*

[10] Van der Keur D. (2014) Legal and Gender Issues of Marriage and Divorce in Cambodia, *The Cambodia Law and Policy Journal, Vol 3*

[11] Ngeth Chuon Setha (2018), Gender Equality in Access to Formal Secondary Education in Cambodia

[12] Parsons L. & Lawreniuk S. (2018) Seeing like the stateless: Documentation and the mobilities of liminal citizenship in Cambodia, *Political Geography*, Vol 62 pp 1 - 11

[13] UNDP, USAID (2014) Being LGBT in Asia: Cambodia Country Report, Bangkok

[14] RoCK (Rainbow Community Kampuchea) and TNS Cambodia (2015) '*Research Report on Opinions, Attitudes and Behaviour toward the LGBT Population in Cambodia'*, Phnom Penh: RoCK

[15] Barennes H., Sovann Tat, Reinharz D. & Ung Vibol (2014) Perceived stigma by children on antiretroviral treatment in Cambodia, *BMC Pediatrics 2014, 14:300*

[16] CEDAW https://www.un.org/womenwatch/daw/cedaw/

**រក្សាសិទ្ធិដោយ៖** នាយកដ្ឋានគោលនយោបាយ ក្រសួងអប់រំ យុវជន និងកីឡា

**អាសយដ្ឋាន៖** អគារ ១៦៩ មហាវិថីព្រះនរោត្តម ខណ្ឌចំការមន រាជធានីភ្នំពេញ

**វេបសាយ:** www.dopomoeys.com